# គ.ជ.អ.ប

## អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ

## ក្រសួងផែនការ

---

# ក្របខ័ណ្ឌគោលនយោបាយផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

## ឯកសារគោលនយោបាយណែនាំតម្រង់ទិស

## ការកែសម្រួលសេចក្ដីណែនាំ និងលិខិតបទដ្ឋានគតិយុត្តបច្ចុប្បន្ន

---

ខែមីនា ឆ្នាំ២០១២

# ពាក្យបំព្រួញ និងអក្សរកាត់

| | |
|---|---|
| C/S | ឃុំ សង្កាត់ |
| D/M/K | ស្រុក/ក្រុង/ខណ្ឌ |
| DMF | មូលនិធិក្រុង /ស្រុក |
| IP | កម្មវិធីវិនិយោគ |
| LDA | របៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន |
| LUMP | ផែនការគ្រប់គ្រងការប្រើប្រាស់ដីធ្លី |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MOI | ក្រសួងមហាផ្ទៃ |
| MOP | ក្រសួងផែនការ |
| NA | រដ្ឋបាលថ្នាក់ជាតិ |
| OL | ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| PBC | គណៈកម្មាធិការកសាងផែនការ និងថវិកា |
| PWG | ក្រុមការងារកសាងផែនការ |
| SDF | ក្របខ័ណ្ឌបែងចែកតំបន់អភិវឌ្ឍន៍ |
| 5YDP | ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ |
| SNA | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| SOP | កម្មវិធីប្រតិបត្តិការសេវាកម្ម |
| TFC | គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស |

# មាតិកា

ពាក្យបំព្រួញ និងអក្សរកាត់ .... 2

ក/គោលបំណង និងវិសាលភាពឯកសារគោលនយោបាយ .... 5

ខ /មូលហេតុអ្វីបានជាចាំបាច់ត្រូវកែសម្រួលលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចុប្បន្ន? .... 6

គ /គោលការណ៍នៃផែនការថ្នាក់ក្រោមជាតិតាមប្រព័ន្ធវិមជ្ឈការ .... 9

១–ផែនការ និងស្វ័យភាពមូលដ្ឋាន .... 9

២–ផែនការ និងអភិបាលកិច្ចច្រើនថ្នាក់ .... 9

៣–ការកសាងផែនការតាមប្រព័ន្ធដែនដីផ្សេងៗគ្នា .... 10

ឃ/សំណើក្របខ័ណ្ឌគោលនយោបាយផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ .... 10

១–ប្រព័ន្ធកសាងផែនការ .... 10

២–ស្ថាប័នកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ .... 11

២.១–គណៈកម្មាធិការផែនការ និងថវិកា(គផថ)របស់ក្រុមប្រឹក្សា .... 12

២.២–វេទិកាកសាងផែនការ .... 12

២.៣–ក្រុមការងារកសាងផែនការ (កកផ) .... 13

៣–ឧបករណ៍សម្រាប់កសាងផែនការ និងរៀបចំកម្មវិធីតាមវិស័យ .... 14

៣.១–ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (5YDP) .... 14

៣.២–របៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន .... 15

៣.៣–កម្មវិធីវិនិយោគ (IP) .... 15

៣.៤–កម្មវិធីប្រតិបត្តិការសេវាកម្ម (SOP) .... 16

៤–ដំណើរការកសាងផែនការ និងរៀបចំកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ .... 16

៤.១–ដំណើរការកសាងផែនការ ..... 16

៤.២–ដំណើរការរៀបចំកម្មវិធីវិនិយោគ ..... 19

៥–ក្របខណ្ឌពេលវេលាក្នុងការរៀបចំកម្មវិធី និងកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ..... 20

៦–ប្រព័ន្ធគាំទ្រការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ..... 21

៦.១–ក្រសួងផែនការ (MOP) ..... 21

៦.២–ក្រសួងមហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (MOI/DOLA) ..... 22

៦.៣–ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ..... 22

៦.៤–ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ អគ្គនាយកដ្ឋានរតនាគារជាតិ(MEF/GDNT) ..... 23

## ក/គោលបំណង និងវិសាលភាពឯកសារគោលនយោបាយ

គោលបំណងនៃឯកសារនេះ គឺដើម្បីផ្ដល់ការណែនាំតម្រង់ទិសគោលនយោបាយក្នុងការកែទម្រង់ប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ជាពិសេសឯកសារនេះជួយតម្រង់ទិសដល់ការកែសម្រួលគោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តបច្ចុប្បន្ន និងជួយផ្លាស់ប្ដូរប្រព័ន្ធផែនការមជ្ឈការឱ្យទៅជាប្រព័ន្ធផែនការវិមជ្ឈការ ដែលរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចែករំលែកការទទួលខុសត្រូវអាណត្តិរបស់ខ្លួន ហើយផែនការនៃរដ្ឋបាលនីមួយៗដំណើរការទៅផ្សេងៗគ្នាតែមានការសម្របសម្រួលជាមួយគ្នាដើម្បីលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

ការកែសម្រួលគោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តបច្ចុប្បន្ន គឺស្ថិតនៅក្រោមការទទួលខុសត្រូវ និងគ្រប់គ្រងចាត់ចែងដោយអនុកម្មវិធីទី៥នៃផអ៣ ហើយការកែសម្រួលនេះរំពឹងថានឹងបញ្ចប់ក្នុងក្របខ័ណ្ឌពេលវេលារបស់ផអ៣ (២០១១-២០១៣)។

ឯកសារនេះបរិយាយអំពីសមាសភាគមូលដ្ឋានក្នុងការកែសម្រួលប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសំណើផ្លាស់ប្ដូរ ស្ថាប័ន ឧបករណ៍ ដំណើរការ ក្របខ័ណ្ឌពេលវេលា និងប្រព័ន្ធគាំទ្រផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

បន្ទាប់ពីការអនុម័តគោលនយោបាយផែនការដោយ គ.ជ.អ.ប លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ សៀវភៅណែនាំនឹងត្រូវរៀបចំបង្កើតឡើង។ ការកែសម្រួលគោលនយោបាយនេះនឹងមិនមានភាពស្មុគស្មាញទេ ដោយសារតែវាផ្ដោតតែទៅលើការរៀបចំទស្សនទាន និងរចនាសម្ព័ន្ធនៃផែនការកម្រិតផ្សេងៗគ្នារបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងមិនសំដៅទៅលើការកែសម្រួលវិធីសាស្ត្រ និងបច្ចេកទេសកសាងផែនការឡើយ។ ការអភិវឌ្ឍសមត្ថភាពស្ដីពីការកសាងផែនការនៅថ្នាក់មូលដ្ឋាននឹងបន្តពង្រឹងបន្ថែមទៅលើបទពិសោធន៍ដែលបានអនុវត្តតាំងពីឆ្នាំ២០០៩ មក។

ក្នុងឯកសារគោលនយោបាយនេះ ពាក្យថា “ផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ” គឺសំដៅទៅលើការរៀបចំកម្មវិធី និងផែនការអភិវឌ្ឍន៍ពហុវិស័យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ។

វិសាលភាពនៃឯកសារនេះបានកំណត់តាមគោលបំណងចង់បាន ដោយផ្អែកលើសារៈសំខាន់ ភាពចាំបាច់ និងអាចធ្វើទៅបាន។ ឯកសារនេះមិនគ្របដណ្ដប់ដោយផ្ទាល់ទៅលើការរៀបចំឧបករណ៍ដំណើរការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទេ។

ជាពិសេស៖

(i) ឯកសារនេះមិនគ្របដណ្ដប់លើដំណើរការកសាងផែនការឃុំ សង្កាត់ទេ។ ដំណើរការកសាងផែនការឃុំ សង្កាត់បានអនុវត្តមួយទសវត្សរ៍ ហើយបានទទួលការវាយតម្លៃ និងផ្លាស់ប្ដូរជាច្រើនលើករួចមកហើយ។ ក្នុងដំណាក់កាលបច្ចុប្បន្ននេះ មិនមានការចាំបាច់ក្នុងការកែសម្រួលដំណើរការកសាងផែនការឃុំ សង្កាត់ទេ

ហើយការប៉ុនប៉ងណាមួយក្នុងការកែសម្រួលដំណើរកសាងផែនការឃុំ សង្កាត់នឹងធ្វើឱ្យខាតបង់ធនធាន និងសមត្ថភាពជាតិក្នុងការងារកំណែទម្រង់ស្តីពីដំណើរការកសាងផែនការរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ទោះបីជាយ៉ាងណាក៏ដោយការកែសម្រួលក្របខ័ណ្ឌពេលវេលាកសាងផែនការ កម្មវិធី និងថវិកាឃុំ សង្កាត់ គឺមានការចាំបាច់ដើម្បីបន្សុីគ្នា សម្របសម្រួលគ្នា ឬដាក់បញ្ចូលគ្នាជាមួយការកសាងផែនការ កម្មវិធី និងថវិការបស់ក្រុង ស្រុក ខណ្ឌ។

(ii) ឯកសារនេះមិនគ្របដណ្តប់លើការរៀបចំឧបករណ៍កសាង**<u>ផែនការរូបវ័ន្ត</u>**ទេ។ ទោះបីជាច្បាប់អង្គការបានកំណត់ឱ្យមានការរៀបចំ**<u>ក្របខ័ណ្ឌបែងចែកតំបន់អភិវឌ្ឍន៍</u>**ព្រមពេលជាមួយគ្នានឹងការកសាងផែនការអភិវឌ្ឍន៍រយៈ៥ឆ្នាំ ក៏ប៉ុន្តែមិនទាន់អាចអនុវត្តបាននៅឡើយព្រោះដោយសារតែតម្រូវឱ្យអនុវត្តសាកល្បងឧបករណ៍កសាងផែនការរូបវ័ន្តក្នុងផអពជាមុនសិន មុននឹងការរៀបចំអនុម័តគោលនយោបាយជាក់លាក់ណាមួយក្នុងការកសាង**<u>ផែនការរូបវ័ន្ត និងលិខិតបទដ្ឋានគតិយុត្ត</u>** ("ក្របខ័ណ្ឌបែងចែកតំបន់អភិវឌ្ឍន៍" និង "ផែនការគ្រប់គ្រងការប្រើប្រាស់ដីធ្លី")របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

(iii) ជាទីបញ្ចប់ឯកសារនេះមិនគ្របដណ្តប់លើដំណើរការរៀបចំថវិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទេ ព្រោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងដំណើរការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ដំណើការរៀបចំថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ស្វ័យភាពរៀបចំថវិការបស់ក្រុង ស្រុក ក្នុងវិស័យសាធារណៈនៅកម្ពុជា គឺជាចំនុចចាប់ផ្តើមក្នុងការកែសម្រួលដំណើរការកសាងផែនការ កម្មវិធី។ ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តឧបករណ៍ និងក្របខ័ណ្ឌពេលវេលាក្នុងរៀបចំថវិកានឹងពាក់ព័ន្ធជាមួយជាមួយនឹងដំណើរការកសាងផែនការ កម្មវិធី។

## ២/មូលហេតុអ្វីបានជាចាំបាច់ត្រូវកែសម្រួលលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចុប្បន្ន?

បច្ចុប្បន្ននេះ ដំណើរការកសាងផែនការ កម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់ និងគាំទ្រដោយច្បាប់អង្គការ ។ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំទាំងនោះមានដូចតទៅះ

- **<u>អនុក្រឹត្យលេខ ២១៩</u>** ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៩)
- **<u>អនុក្រឹត្យលេខ ២១៧</u>** ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានី និងខណ្ឌ
- **<u>អនុក្រឹត្យលេខ ២១៨</u>** ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត ក្រុង និងស្រុក

- <u>**សេចក្ដីណែនាំបច្ចេកទេស**</u> ស្ដីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- <u>**សេចក្ដីណែនាំបច្ចេកទេស**</u> ស្ដីពីការកសាងកម្មវិធីវិនិយោគរាជធានី ខេត្ត
- <u>**សេចក្ដីណែនាំបច្ចេកទេស**</u> ស្ដីពីការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- <u>**សេចក្ដីណែនាំបច្ចេកទេស**</u> ស្ដីពីការកសាងកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ។

ក្នុងឆ្នាំ២០០៩ ដោយសារពេលវេលាមិនអំណោយផល លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាត្រូវបានបង្កើតឡើងយ៉ាងប្រញាប់ប្រញាល់ ដើម្បីធានាថារដ្ឋបាលថ្នាក់ក្រោមជាតិដែលទើបនឹងបង្កើតថ្មីអាចអនុវត្តកាតព្វកិច្ច[1] របស់ខ្លួនក្នុងការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលនៅក្នុងឆ្នាំទី១នៃអាណត្តិជាប់ឆ្នោតរបស់ខ្លួន។

ទោះបីជាយ៉ាងណាក៏ដោយ ការកសាងផែនការ និងកម្មវិធីវិនិយោគលើកទី១ ក្រុង ស្រុក ពុំទាន់មានលទ្ធភាពក្នុងការអនុវត្តស្វ័យភាពថវិកានៅឡើយទេ ដោយសារតែៈ (ក)ខ្វះខាតក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ និង (ខ)ការពន្យាពេលការអនុម័តមូលនិធិក្រុង ស្រុក និងការផ្ទេរធនធានដែលអាចអនុវត្តកម្មវិធីនៅមូលដ្ឋាន។

ដោយសារតែល័ក្ខខ័ណ្ឌខាងលើបានធ្វើឱ្យវិសាលភាពក្នុងការអនុវត្តផែនការរបស់ក្រុង ស្រុក ត្រូវបានកំណត់ក្នុងព្រំដែនមួយ និងដោយគ្មានធនធានផ្ទាល់ខ្លួន ក្រុង ស្រុកមានការលំបាកក្នុងការកសាងផែនការរបស់ខ្លួន ដូច្នេះក្រុង ស្រុកបានត្រឹមតែព្យាយាមបញ្ចុះបញ្ចូលការវិភាជន៍ធនធានពីអ្នកពាក់ព័ន្ធផ្សេងៗទៀត (ស្ថាប័ននានា របស់រដ្ឋបាលថ្នាក់ជាតិ អង្គការ និងអ្នកផ្ដល់ជំនួយនានា)។

លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចុប្បន្នពុំបានបង្ហាញពីភាពខុសគ្នារវាងធនធានរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយបានបន្តអនុវត្តផែនការរបស់ថ្នាក់ក្រោមជាតិថាជាដំណើរការមួយ"ក្នុងការប្រែក្លាយផែនការជាតិឱ្យទៅជាផែនការសម្រាប់អនុវត្តក្នុងមូលដ្ឋាន" និងមិនបានផ្ដល់សារៈសំខាន់ដល់ដំណើរការ"កសាងផែនការផ្ទាល់របស់ថ្នាក់ក្រោមជាតិ"ដែលបានឆ្លុះបញ្ចាំងនូវស្វ័យភាពជម្រើសគោលនយោបាយរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងការកៀរគរ វិភាជន៍ និងគ្រប់គ្រងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយផ្ទាល់។

ការងារដ៏សំខាន់ក្នុងគោលនយោបាយផែនការថ្មីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺការកែតម្រូវទស្សនៈយល់ច្រឡំទាំងនោះ។ គោលនយោបាយថ្មីនេះនឹងជួយតម្រង់ទិសការបង្កើតលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំថ្មីដែលផ្អែកលើការបកស្រាយក្នុងច្បាប់អង្គការ និងកំណត់ច្បាស់លាស់អំពីផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការកៀរគរ ការវិភាជន៍ធនធានទាំងពីរប្រភេទ ពីអ្នកពាក់ព័ន្ធផ្សេងៗ និងវិភាជន៍ធនធានផ្ទាល់របស់ខ្លួន។ យោងតាមស្មារតីច្បាប់អង្គការ គឺបានគាំទ្រប្រភេទទាំង២នេះ ប៉ុន្តែប្រភេទទី២ពុំមានការបកស្រាយច្បាស់លាស់ក្នុងអត្ថបទច្បាប់ទេ។

ផ្អែកតាមច្បាប់អង្គការ (ផ្នែកទី២ មាត្រា ៣៦-៣៩) បានកំណត់អាណត្តិរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកសាង

---

[1] យោងច្បាប់អង្គការមាត្រា ៣៩

ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំ(៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ"រួមទាំងសមាសភាពនៃផែនការ ដែលស្ថិតនៅក្រោមការគ្រប់គ្រងនិងត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួងនិងស្ថាប័នរបស់រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា" (មាត្រា ៣៦)។

យោងតាមច្បាប់អង្គការ តម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកសាងផែនការ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ (ប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗទៀត និងឃុំ សង្កាត់ មន្ទីរជំនាញផ្សេងៗ វិស័យឯកជន និងសហគមន៍ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន) ដែលមានបំណងចូលរួមក្នុងដំណើរការពិគ្រោះយោបល់ និងចរចាក្នុងការប្រើប្រាស់បំពេញធនធានបន្ថែមសម្រាប់អភិវឌ្ឍន៍ក្នុងមូលដ្ឋាន។

ផែនការនេះគឺជា "ផែនការតាមដែនសមត្ថកិច្ច" ឬ "ផែនការតាមដែនសមត្ថកិច្ចទូទៅ" ពីព្រោះផែនការនេះនឹងត្រូវអនុវត្តពីគ្រប់ភាគីពាក់ព័ន្ធស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ហើយផែនការនេះមានវិសាលភាពក្នុងការសម្របសម្រួលសកម្មភាពជាមួយវិស័យសាធារណៈ វិស័យឯកជន និងអង្គការនានា ដែលកំពុងតែធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ផែនការតាមដែនសមត្ថកិច្ច មានសារៈសំខាន់ និងកំពុងតែអនុវត្តច្រើនឡើងទូទាំងពិភពលោក។ ទោះបីជាយ៉ាងណាក៏ដោយ វាមិនមានន័យថាត្រូវជំនួសផែនការផ្សេងៗទេ ប៉ុន្តែវាគ្រាន់តែបំពេញបន្ថែម និងសម្របសម្រួលជាមួយប្រភេទផែនការផ្សេងៗទៀត។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមាន"ផែនការផ្ទាល់របស់ខ្លួន"ដែលរៀបចំឡើងតាមរយៈការពិគ្រោះយោបល់ ចរចា និងការវិភាជន៍ធានធានផ្ទាល់ខ្លួននៅក្នុងដែនសមត្ថកិច្ចទូទៅ។

នៅពេលដែលផែនការតាមដែនសមត្ថកិច្ច និង**ផែនការផ្ទាល់**របស់រដ្ឋបាលថ្នាក់ក្រោមជាតិបានប្រព្រឹត្តទៅក្នុងដំណើរការតែមួយដោយមានការសម្របសម្រួលជាមួយគ្នា ពេលនោះផែនការ និងកម្មវិធីជាក់ស្តែងនឹងមិនមានការច្រឡំចូលគ្នាទៀតឡើយ។

ផែនការកម្រិតផ្សេងៗគ្នា គឺមានសារៈសំខាន់ណាស់ក្នុងការធានាបាននូវគណនេយ្យភាព។ រដ្ឋបាលថ្នាក់ក្រោមជាតិគួរតែលើកកម្ពស់ថាមពលរួមគ្នារវាងការប្រឹងប្រែងផ្ទាល់ខ្លួនជាមួយនឹងរដ្ឋបាលថ្នាក់ជាតិ អង្គការ វិស័យឯកជន ហើយរដ្ឋបាលថ្នាក់ក្រោមជាតិមានគណនេយ្យភាពក្នុងការកសាងនិងអនុវត្តផែនការ កម្មវិធី និងថវិកា "ផែនការផ្ទាល់" និងមិនអនុវត្តផែនការតាមដែនសមត្ថកិច្ចទូទៅទេ។

បច្ចុប្បន្ន ច្បាប់អង្គការទទួលស្គាល់**ផែនការតាមដែនសមត្ថកិច្ច**របស់រដ្ឋបាលថ្នាក់ក្រោមជាតិ "រួមទាំងសមាសភាពនៃផែនការ ដែលស្ថិតនៅក្រោមការគ្រប់គ្រងនិងត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួងនិងស្ថាប័នរបស់រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា" (មាត្រា ៣៦)។ តែច្បាប់អង្គការមិនបានបញ្ជាក់ច្បាស់ពីភាពខុសគ្នារវាងផែនការទាំងនោះជាមួយ**ផែនការផ្ទាល់**របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកសាងផែនការដើម្បីតម្រង់ទិសការអនុវត្តសកម្មភាព និងការវិភាជន៍ធនធានផ្ទាល់ខ្លួន។ ភាពខ្វះចន្លោះក្នុងក្របខ័ណ្ឌច្បាប់នេះ

គួរតែត្រូវបានបំពេញបន្ថែមដោយការកែសម្រួលគោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តនៃការកសាងផែនការ ដូចដែលបានកំណត់ក្នុងច្បាប់អង្គការ(មាត្រា៣៩)។

## គ/គោលការណ៍នៃផែនការថ្នាក់ក្រោមជាតិតាមប្រព័ន្ធវិមជ្ឈការ

### ១–ផែនការ និងស្វ័យភាពមូលដ្ឋាន

ច្បាប់អង្គការបានបង្កើតរដ្ឋបាលថ្នាក់ក្រោមជាតិជា "នីតិបុគ្គល" ដែលដំណើរការក្នុងក្របខ័ណ្ឌច្បាប់ជាតិ និងស្ថិតក្រោមការត្រួតពិនិត្យនីត្យានុកូលភាពរបស់រដ្ឋ។ ព្រំដែនស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត និងច្បាប់ជាតិ ហើយភ្នាក់ងារនៃរដ្ឋបាលថ្នាក់ជាតិទទួលខុសត្រូវគ្រប់គ្រងត្រួតពិនិត្យ។

ទោះបីជាយ៉ាងណាក៏ដោយនៅក្នុងព្រំដែនកំណត់នោះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែមានស្វ័យភាពពេញលេញក្នុងការរៀបចំគោលនយោបាយមូលដ្ឋាន ការកៀរគរធនធាន និងការគ្រប់គ្រងចំណាយសាធារណៈ។ ស្វ័យភាពបែបនេះគឺមានសារៈសំខាន់ណាស់ បើគ្មានស្វ័យភាពរដ្ឋបាលថ្នាក់ក្រោមជាតិនឹងមិនមានសេរីភាពក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការផ្តួចផ្តើម និងការកៀរគរធនធានបន្ថែមក្នុងមូលដ្ឋាន ឬពង្រឹងប្រសិទ្ធភាពការទទួលខុសត្រូវក្នុងការអនុវត្តធនធានដែលប្រគល់ឱ្យដោយថ្នាក់ជាតិ។ បើគ្មានស្វ័យភាពរឹងមាំទេ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងមិនមានលទ្ធភាពផ្តល់ប្រយោជន៍ក្នុងការអភិវឌ្ឍទៅតាមការរំពឹងទុកនៃកំណែទម្រង់វិមជ្ឈការឡើយ។ប្រព័ន្ធអភិបាលកិច្ចច្រើនថ្នាក់ដែលកំណត់ដោយច្បាប់អង្គការបានរំពឹងថារដ្ឋបាលថ្នាក់ក្រោមជាតិនឹងអនុវត្តតួនាទីពីរ៖

- រដ្ឋបាលថ្នាក់ក្រោមជាតិគួរតែអនុវត្តឱ្យមានប្រសិទ្ធភាពក្នុងការផ្តល់សេវាកម្មនានា និងតួនាទីជាក់លាក់សម្រាប់វិស័យផ្សេងៗទៀតដែលចាត់តាំង ឬប្រតិភូកម្មឱ្យដោយរដ្ឋបាលថ្នាក់ជាតិ។
- រដ្ឋបាលថ្នាក់ក្រោមជាតិ គួរតែអនុវត្តអំណាចស្វ័យភាពរបស់ខ្លួនក្នុងការសម្រេចប្រើប្រាស់ធនធានដែលផ្ទេរឱ្យដោយថ្នាក់ជាតិ ឬធនធានផ្ទាល់ខ្លួន និងមុខងារជាជម្រើសរបស់ខ្លួន ដើម្បីឆ្លើយតបតម្រូវការជាអាទិភាពក្នុងមូលដ្ឋាន។

នៅក្នុងតួនាទីទី១ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងអនុវត្តមុខងារជាក់លាក់ដែលប្រតិភូកម្ម ឬប្រគល់អំណាចឱ្យដោយរដ្ឋបាលថ្នាក់ជាតិ។ តួនាទីទី២ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងអនុវត្តមុខងារជាជម្រើសរបស់ខ្លួន ដើម្បីឆ្លើយតបអាណត្តិទូទៅ ដូចដែលបានចែងក្នុងច្បាប់អង្គការក្នុងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យក្នុងមូលដ្ឋាន។

### ២–ផែនការ និងអភិបាលកិច្ចច្រើនថ្នាក់

កំណែទម្រង់វិមជ្ឈការកំពុងតែផ្លាស់ប្តូរអភិបាលកិច្ចរបស់ប្រទេស ប្រព័ន្ធរដ្ឋបាលសាធារណៈឱ្យទៅជាប្រព័ន្ធច្រើនកម្រិត ដែលនីតិបុគ្គលនីមួយៗទទួលខុសត្រូវក្នុងការរៀបចំគោលនយោបាយ និងអនុវត្តកិច្ចសហការក្នុងកម្រិតនីមួយៗ និងកម្រិតផ្សេងគ្នាទៅតាមរចនាសម្ព័ន្ធរបស់រដ្ឋ/ប្រទេស។

នៅក្នុងប្រព័ន្ធបែបនេះ រដ្ឋបាលថ្នាក់ជាតិមិនមែនជាអ្នកទទួលខុសត្រូវផ្តាច់មុខទៀតឡើយក្នុងការកសាងផែនការ ការផ្តល់សេវាកម្មនិងហិរញ្ញវត្ថុ និងការលើកកម្ពស់ការអភិវឌ្ឍ ប៉ុន្តែជាការចែករំលែកការទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាពរវាងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងស្ថាប័នផ្សេងៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

យន្តការចាស់ដែលគ្រប់គ្រងតាមរចនាសម្ព័ន្ធរដ្ឋបាល និងអភិបាលកិច្ចតែមួយ(វិមជ្ឈការ)នោះនឹងមិនអាចអនុវត្តបានចំពោះស្ថាប័នរដ្ឋបាល និងអភិបាលកិច្ច (វិមជ្ឈការ)ច្រើនថ្នាក់បានទេ ដូច្នេះត្រូវជំនួសដោយយន្តការមួយថ្មីដែលមានការពិគ្រោះយោបល់ និងចរចាដូចជាការត្រួតពិនិត្យនីត្យានុកូលភាពទៅតាមស្វ័យភាពរបស់នីតិបុគ្គលថ្មីនានា។

ក្នុងការអនុវត្តបច្ចុប្បន្ននេះ មានស្ថាប័នជាច្រើនកម្រិតកំពុងតែដំណើរការកសាងផែនការ កម្មវិធី និងថវិកានៅក្នុងបរិបទវិមជ្ឈការវិស័យសាធារណៈ ហើយកំពុងតែស្មុគស្មាញក្នុងការសម្របសម្រួល ដែលកម្ពុជាត្រូវពិចារណាឡើងវិញនូវប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ការកែសម្រួលគោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយរួមបញ្ចូលគ្នារវាង (១)ឧបករណ៍ និងដំណើរការកសាងផែនការស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹង (២)យន្តការសម្របសម្រួលខ្សែទទឹង និងខ្សែបណ្តោយរបស់ថ្នាក់ក្រោមជាតិជាមួយអ្នកពាក់ព័ន្ធគ្រប់កម្រិត (ភ្នាក់ងាររដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗទៀត និងឃុំសង្កាត់ វិស័យឯកជននិងអង្គការនានា) នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ជាឱកាសដ៏ល្អ ដោយសារតែនេះមិនមែនជារឿងថ្មីទាំងស្រុងទេសម្រាប់ប្រទេសកម្ពុជា។ អស់រយៈពេលមួយទសវត្សរ៍មកហើយ ឃុំ សង្កាត់បានរួមបញ្ចូលដំណើរការកសាងផែនការរបស់ខ្លួនតាមយន្តការពិគ្រោះយោបល់ និងចរចាជាមួយរដ្ឋបាលថ្នាក់ជាតិនៅក្នុង"សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក"(DIW)។ បទពិសោធន៍ដែលទទួលបានពីឃុំ សង្កាត់ នឹងជួយដល់ការរៀបចំគោលការណ៍ណែនាំដំណើរការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៣-ការកសាងផែនការតាមប្រព័ន្ធដែនដីផ្សេងៗគ្នា

រដ្ឋបាលថ្នាក់ក្រោមជាតិមិនមែនជារចនាសម្ព័ន្ធតាមឋានានុក្រមរបស់រដ្ឋបាលថ្នាក់ជាតិឡើយ ប៉ុន្តែរដ្ឋបាលថ្នាក់ក្រោមជាតិ ជានីតិបុគ្គលមួយថ្មីដែលមានប្រព័ន្ធរដ្ឋបាល និងអភិបាលកិច្ចដាច់ដោយឡែក។ ប្រព័ន្ធនេះត្រូវបានរៀបចំឡើងទៅតាមអនុប្រព័ន្ធដែនដីផ្សេងៗគ្នា ដោយផ្អែកលើលក្ខណៈខុសប្លែកគ្នារបស់មូលដ្ឋាន ប្រជុំជន និងជនបទ ដូចដែលបានកំណត់ក្នុងច្បាប់អង្គការ។ រដ្ឋបាលថ្នាក់ក្រោមជាតិនានាមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមក និងទៅឃុំ សង្កាត់។ ការគ្រប់គ្រងនឹងអនុវត្តទៅតាមអនុប្រព័ន្ធដែនដីនីមួយៗរួមមាន៖ (១)រាជធានីភ្នំពេញ (២)ខេត្ត (៣)ក្រុង និង(៤)ស្រុក។

## ឃ/សំណើក្របខ័ណ្ឌគោលនយោបាយផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ១-ប្រព័ន្ធកសាងផែនការ

គួររៀបចំឡើងវិញនូវ លិខតិបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ សៀវភៅណែនាំ និងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព

របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យស្របទៅតាមអនុប្រព័ន្ធតាមដែនដីទាំង៤ប្រភេទ និងប្រភេទផែនការដែលពាក់ព័ន្ធ៖

- **ផែនការតំបន់** អនុវត្តសម្រាប់ខេត្ត
- **ផែនការរាជធានី** អនុវត្តសម្រាប់រាជធានីភ្នំពេញ ខណ្ឌ និងសង្កាត់
- **ផែនការប្រជុំជន** អនុវត្តសម្រាប់ក្រុង និងសង្កាត់
- **ផែនការជនបទ** អនុវត្តសម្រាប់ស្រុក និងឃុំ សង្កាត់។

សម្រាប់ពេលបច្ចុប្បន្ននេះ ដំណាក់កាលដំបូងក្នុងការបង្កើតប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺការរៀបចំស្ថាប័នទៅតាមប្រភេទនៃផែនការនីមួយៗ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងឃុំ សង្កាត់មានលទ្ធភាពសម្របសម្រួលជាមួយគ្នា និងដាក់បញ្ចូលគ្នានូវផែនការ កម្មវិធីដែលប្រើប្រាស់ធនធានក្នុងអនុប្រព័ន្ធតាមដែនដីជាក់លាក់នីមួយៗ។

តាមរយៈលំហាត់កសាងផែនការតំបន់ ខេត្តត្រូវបានរំពឹងថានឹងធ្វើការសម្របសម្រួលផែនការ និងកម្មវិធីរបស់ខ្លួនជាមួយក្រុង ស្រុក ហើយខេត្តនឹងរៀបចំផែនការបំពេញបន្ថែមទៅនឹងផែនការដែលបានរៀបចំដោយក្រុង ស្រុក ដែលមិនមែនជាការបូកសរុបផែនការដែលរៀបចំដោយក្រុង ស្រុក ទេ។

ដោយគោរពទៅតាមស្វ័យភាពរបស់ ខណ្ឌ និងសង្កាត់ រាជធានីភ្នំពេញត្រូវបានរំពឹងទុកថាត្រូវជៀសវាងការផ្តល់សេវាកម្ម និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដាច់ដាក់ណាត់ៗ។ រាជធានីភ្នំពេញគួរតែប្រើប្រាស់ឥទ្ធិពលបញ្ចុះបញ្ចូលក្នុងការកសាងផែនការ ខណ្ឌ និងសង្កាត់ ឱ្យដាក់បញ្ចូលគ្នាទៅជា ផែនការ កម្មវិធី និងថវិកាឯកភាពរបស់រាជធានី។

ដោយមានមូលហេតុប្រហាក់ប្រហែលគ្នា ក្រុង ស្រុក ត្រូវបានរំពឹងទុកថានឹងធ្វើសកម្មភាពដ៏រឹងមាំជាមួយឃុំ សង្កាត់ក្នុងការរៀបចំផែនការ និងការដាក់បញ្ចូលផែនការរបស់សង្កាត់ក្នុងផែនការ កម្មវិធី ថវិការបស់ក្រុង/ប្រជុំជន។

ជាចុងក្រោយ ស្រុកត្រូវបានរំពឹងទុកថានឹងធ្វើការសម្របសម្រួលផែនការ កម្មវិធីរបស់ខ្លួនជាមួយនិងឃុំ សង្កាត់។ ផែនការ កម្មវិធី កម្រិតស្រុក(ជនបទ) មិនជំនួសឱ្យផែនការឃុំ សង្កាត់ទេ ហើយក៏មិនមែនជាការបូកសរុបផែនការឃុំ សង្កាត់ដែរ ប៉ុន្តែជួយផ្តល់ការលើកទឹកចិត្តក្នុងការធ្វើសម្ពភាពរួមគ្នាជាមួយឃុំ សង្កាត់ និងការវិភាជន៍ថវិកាបំពេញបន្ថែម និងការលើកម្ពស់ការអភិវឌ្ឍដែលអនុវត្តដោយឃុំ សង្កាត់ ។

## ២–ស្ថាប័នកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំថ្មីក្នុងការកសាងផែនការរបស់រដ្ឋាបាលថ្នាក់ក្រោមជាតិនឹងមានភាពសាមញ្ញ ហើយបញ្ជាក់ច្បាស់នូវស្ថាប័នកសាងផែនការនៅកម្រិតនីមួយៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាថ្មីម្តងទៀត ការងារដែលបន្ទាន់បំផុត គឺការរៀបចំបង្កើតស្ថាប័នគាំទ្រស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមិនប៉ះពាល់ដល់ស្ថាប័នវិសហមជ្ឈការរបស់រដ្ឋបាលថ្នាក់ជាតិ ហើយស្ថាប័នបង្កើតថ្មីនោះនឹងសម្របសម្រួលកិច្ចសហការរវាងប្រព័ន្ធទាំងពីរ។ រៀបចំតួនាទីរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ឱ្យទៅជារចនាសម្ព័ន្ធមានមុខងារចំនួនពាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ៖

- គណៈកម្មាធិការផែនការ និងថវិការបស់ក្រុមប្រឹក្សា
- វេទិកាកសាងផែនការ
- ក្រុមការងារកសាងផែនការ។

### ២.១–គណៈកម្មាធិការផែនការនិងថវិកា (គផថ)របស់ក្រុមប្រឹក្សា

ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មិនមែនគ្រាន់តែជាដំណើរការបច្ចេកទេសមួយ ហើយបញ្ចប់នៅត្រឹមការងាររដ្ឋបាលទេ ការកសាងផែនការជាដំណើរការនយោបាយដែលតម្រូវឱ្យក្រុមប្រឹក្សាចូលរួមជាបន្តបន្ទាប់។ ក្រុមប្រឹក្សាគួរបង្កើតគណៈកម្មាធិការជំនាញផែនការ និងថវិកា (គផថ) ដែលមានសមាសភាពមកពីតំណាងក្រុមប្រឹក្សា និងអ្នកជំនាញបច្ចេកទេស ដើម្បីជួយសម្របសម្រួល វិភាគគោលនយោបាយ និងផ្តល់ព័ត៌មានដល់ក្រុមប្រឹក្សា។ គណៈកម្មាធិការនេះ[2]មានសារៈសំខាន់ដូចតទៅ៖

(i) ជួយក្រុមប្រឹក្សាឱ្យបានចូលរួមពេញលេញក្នុងដំណើរការកសាងផែនការ ដែលមិនមែនគ្រាន់តែចូលរួមនៅពេលចាប់ផ្តើមនិងពេលបញ្ចប់ទេ។

(ii) អភិវឌ្ឍន៍សមត្ថភាពដល់តំណាងក្រុមប្រឹក្សាក្នុងការគ្រប់គ្រងត្រួតពិនិត្យដំណើរការកសាងផែនការ និងការវាយតម្លៃលទ្ធផល។ គណៈកម្មធិការកសាងផែនការ និងថវិកាជួយផ្តល់ព័ត៌មាន និងវិភាគជូនដល់ក្រុមប្រឹក្សា ក្នុងការធ្វើសេចក្តីសម្រេចបានសមស្រប។

(iii) ជួយសម្របសម្រួលសកម្មភាពរវាងក្រុមប្រឹក្សាកម្រិតផ្សេងៗគ្នារបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅវិញទៅមក និងក្រុមប្រឹក្សាឃុំ សង្កាត់ តាមរយៈកិច្ចប្រជុំរួមគ្នា និងការផ្តល់អនុសាន៍រួមគ្នាដើម្បីទទួលបានសេចក្តីសម្រេចចុងក្រោយពីក្រុមប្រឹក្សាកម្រិតផ្សេងៗគ្នា។

លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំថ្មីគួរតែបំពេញភាពចន្លោះប្រហោងបច្ចុប្បន្ន និងការបង្កើតគណៈកម្មាធិការផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិត។

### ២.២–វេទិកាកសាងផែនការ

ច្បាប់អង្គការបានរំពឹងទុកថានឹងមានការកសាងផែនការដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធតាមរយៈការបង្កើតយន្តការទូលំទូលាយមួយសម្រាប់ការចូលរួម ការពិគ្រោះយោបល់ និងការចរចាររវាងគ្រប់ភាគីពាក់ព័ន្ធ។ យន្តការបែបនេះគឺជាវេទិកាអចិន្ត្រៃយ៍សម្រាប់កសាងផែនការ។

- វេទិកាកសាងផែនការខេត្តគួរតែដឹកនាំដោយអភិបាលខេត្ត ហើយមានសមាសភាពដូចតទៅ៖
  - អភិបាលក្រុងស្រុកទាំងអស់ក្នុងខេត្ត

2 បានបង្កើតគ្រប់ឃុំ សង្កាត់

- ប្រធានគណៈកម្មាធិការផែនការនិងថវិការបស់ក្រុមប្រឹក្សាខេត្ត
- តំណាងអង្គការនានាដែលប្រតិបត្តិការក្នុងខេត្ត (ចំនួនមិនតិចជាង X% នៃកៅអីសរុប)
- តំណាងមន្ទីរជំនាញនានាក្នុងខេត្ត
- ផ្សេងៗ (តំណាងក្រុមប្រឹក្សា) ។

– វេទិកាកសាងផែនការក្រុង ស្រុក គួរតែដឹកនាំដោយអភិបាលក្រុង ស្រុក ហើយមានសមាសភាពដូចតទៅៈ
  - ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងក្រុង ស្រុក
  - ប្រធានគណៈកម្មាធិការផែនការ និងថវិការបស់ក្រុមប្រឹក្សាស្រុក ក្រុង
  - តំណាងអង្គការនានាដែលប្រតិបត្តិការក្នុងស្រុក ក្រុង (ចំនួនមិនតិចជាង X% នៃកៅអីសរុប)
  - តំណាងការិយាល័យជំនាញនានាក្នុងស្រុក ក្រុង
  - ផ្សេងៗ (តំណាងក្រុមប្រឹក្សា) ។

វេទិកាកសាងផែនការ គួរបង្កើតឱ្យមានអនុគណៈកម្មាធិការតាមវិស័យ (ឧទាហរណ៍ៈ សង្គមកិច្ច សេដ្ឋកិច្ច បរិស្ថាន រូបវ័ន្ត/ហេដ្ឋារចនាសម្ព័ន្ធ និងស្ថាប័ន) ដើម្បីផ្តោតការយកចិត្តដាក់ទៅលើវិស័យនីមួយៗក្នុងលំហាត់រៀបចំផែនការយុទ្ធសាស្ត្រ។

វេទិកាកសាងផែនការ គួរបង្កើតទៅជារចនាសម្ព័ន្ធអចិន្ត្រៃយ៍។ វេទិកាកសាងផែនការនឹងជំនួសគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ហើយពង្រីករចនាសម្ព័ន្ធរបស់ខ្លួនសម្រាប់ការចូលរួមពីសង្គមស៊ីវិល និងវិស័យឯកជន។ វេទិកាកសាងផែនការនឹងដើរតួជាស្ថាប័នសម្រាប់ពិគ្រោះយោបល់ ចរចា និងការឯកភាពលើផែនការនៅថ្នាក់ខេត្តដើម្បីធ្វើការសម្របសម្រួលការងារកសាងផែនការក្នុង"សិក្ខាសាលាសមាហរណកម្ម"ថ្នាក់ ក្រុង/ស្រុក។

### ២.៣–ក្រុមការងារកសាងផែនការ (កកផ)

លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចុប្បន្ន បានបង្កើត"ក្រុមការងារកសាងផែនការ" (កកផ) ដើម្បីដំណើរការដាក់ស្តែងក្នុងការកសាងផែនការ កម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ប៉ុន្តែការបង្កើតក្រុមការងារកសាងផែនការបច្ចុប្បន្ន គឺគ្រាន់តែជាគណៈកម្មាធិការមួយផ្សេងទៀតប៉ុណ្ណោះ មិនមែនជារចនាសម្ព័ន្ធមួយដែលប្រតិបត្តិការទៅបានឡើយ។ ដូច្នេះវាជាការចាំបាច់ណាស់ក្នុងការកែសម្រួលក្រុមការងារកសាងផែនការឱ្យទៅជាស្ថាប័នមួយអាចប្រតិបត្តិការទៅបាន ហើយផ្តល់លទ្ធភាពបត់បែនដល់ក្រុមប្រឹក្សាក្នុងការបង្កើតក្រុមការងារកសាងផែនការ ការកំណត់យកអ្នកសម្របសម្រួល និងសេវាកម្មទីប្រឹក្សា។

កកផ គួរតែជា "ក្រុមការងារពិសេសមួយ" របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមិនមានសមាសភាពបុគ្គលិកចំរុះ

រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។ ក្រុមការងារកសាងផែនការគួររួមបញ្ចូលតំណាង៖

- ទីចាត់ការ/ការិយាល័យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ទីចាត់ការ/ការិយាល័យអន្តរវិស័យ ឬការិយាល័យអភិវឌ្ឍន៍ក្រុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ទីចាត់ការ/ការិយាល័យហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សមាជិកក្រុមប្រឹក្សាដែលជាសមាជិកគណៈកម្មាធិការកសាងផែនការ និងថវិកា (គផថ)។

ការងារគ្រប់គ្រងប្រចាំថ្ងៃរបស់ក្រុមការងារកសាងផែនការគួរស្ថិតនៅក្រោមការដឹកនាំរបស់ទីចាត់ការ/ការិយាល័យផែនការហើយរាយការណ៍ដោយផ្ទាល់ជូនអភិបាល។ ក្រុមការងារកសាងផែនការ គួរតែស្វែងរកការគាំទ្រពីអ្នកសម្របសម្រួល និងអ្នកជំនាញបច្ចេកទេសទៅតាមការចាំបាច់ និងថវិកាដែលអនុម័តដោយក្រុមប្រឹក្សាសម្រាប់ដំណើរការកសាងផែនការ។

ក្រុមសម្របសម្រួលមួយ គួរត្រូវបានបង្កើតឡើងនៅមន្ទីរជំនាញផែនការខេត្ត ដើម្បីគាំទ្រផ្ទាល់ដល់ការកសាងផែនការរាជធានី និងតំបន់/ខេត្ត និងនៅក្រសួងមហាផ្ទៃ/នាយកដ្ឋានអង្គភាពរដ្ឋបាលមូលដ្ឋាន ដើម្បីគាំទ្រផ្ទាល់ដល់ការកសាងផែនការប្រជុំជន/ក្រុងនិងជនបទ/ស្រុក។ ក្រុមសម្របសម្រួលនឹងជួយពង្រឹងសមត្ថភាពក្រុមការងារកសាងផែនការតាមរយៈរៀនផងធ្វើផង។

ការផ្តល់លទ្ធភាពបត់បែនដល់ក្រុមការងារកសាងផែការស្វែងរកជំនួយគាំទ្របច្ចេកទេសពីខាងក្រៅ។ ល័ក្ខខ័ណ្ឌការងារជាក់លាក់មួយគួរត្រូវបានបង្កើតឡើងសម្រាប់សមាជិកក្រុមការងារកសាងផែនការទាំងអស់ ហើយការចាត់តាំងភារកិច្ចគឺបត់បែនទៅតាមសមត្ថភាពជាក់ស្តែង។

## ៣– ឧបករណ៍សម្រាប់កសាងផែនការ និងការរៀបចំកម្មវិធីតាមវិស័យ

លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនឹងជួយដល់រដ្ឋបាលថ្នាក់ក្រោមជាតិបង្កើតឧបករណ៍ចំនួន៤សម្រាប់ការកសាងផែនការតាមវិស័យ រួមមាន៖

- ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ
- របៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន
- កម្មវិធីវិនិយោគ
- កម្មវិធីប្រតិបត្តិការសេវាកម្ម

### ៣.១– ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (5YDP)

ផែការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ បានកំណត់ដោយច្បាប់អង្គការមាត្រា ៣៩។ វាគឺជា “ផែនការតាមដែនសមត្ថកិច្ចទូទៅ” ដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និងការកៀរគរធនធនថវិកាពីវិស័យសាធារណៈ សហគមន៍ និងវិស័យឯកជន។

ច្បាប់បានកំណត់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដឹកនាំកសាងផែនការអភិវឌ្ឍន៍ ដោយសារតែរដ្ឋបាលថ្នាក់ក្រោមជាតិមានការទទួលស្គាល់ពីស្ថាប័នទាំងអស់ដែលកំពង់តែប្រតិបត្តិការនៅមូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជានីតិបុគ្គលមានការទទួលខុសត្រូវជាចម្បងសម្រាប់ការអភិវឌ្ឍក្នុងមូលដ្ឋាន។

គោលការណ៍ណែនាំថ្មី គួរតែជំរុញដំណើរការកសាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ ឱ្យស្របនឹងសំណើដូចខាងក្រោម៖

**៣.២–របៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន**

របៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន គឺជាឧបករណ៍កសាងផែនការរយៈពេល៥ឆ្នាំនិងជា "ផែនការផ្ទាល់" របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានសមាសភាគដូចខាងក្រោម៖

– កម្មវិធីវិនិយោគ
– ប្រតិបត្តិការផ្តល់សេវាកម្ម និង
– បទដ្ឋានគតិយុត្ត

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្តល់ថវិកាគាំទ្រ និងអនុវត្តរបៀបវារៈទាំងនោះទៅតាម (១)ធនធានផ្ទាល់ខ្លួន(២) វិសាលភាពមុខងារដែលប្រគល់ ឬមុខងារជាជម្រើស និង (៣)អំណាចនានាក្នុងរបៀបចំលិខិតបទដ្ឋានគតិយុត្ត។

របៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន គឺជា "កម្មវិធីនយោបាយជាក់ស្តែង" របស់ក្រុមប្រឹក្សាជាប់ឆ្នោតដែលបង្ហាញពីអ្វីដែលក្រុមប្រឹក្សាចង់សម្រេចបានក្នុងអាណត្តិរបស់ខ្លួន និងបង្ហាញពីគណនេយ្យភាពរបស់ក្រុមប្រឹក្សាជាមួយនឹងប្រជាពលរដ្ឋ និងរដ្ឋាភិបាល។ របៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន គឺជាមូលដ្ឋានគ្រឹះសម្រាប់ប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃក្នុងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ជាចុងបញ្ចប់នេះ របៀបវារៈអភិវឌ្ឍន៍មូលដ្ឋានមិនមែនជាផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំទេ។ ដូច្នេះត្រូវប្រែក្លាយរបៀបវារៈអភិវឌ្ឍន៍មូលដ្ឋានឱ្យទៅជាឧបករណ៍រៀបចំកម្មវិធី ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**៣.៣–កម្មវិធីវិនិយោគ** (IP)

កម្មវិធីវិនិយោគ៣ឆ្នាំរំកិល គឺជាឧបករណ៍មួយដែលបានកំណត់ដោយច្បាប់អង្គការ។ បច្ចុប្បន្នកំពុងតែមានការយល់ច្រឡំគួរឱ្យកត់សម្គាល់ទៅលើលក្ខណៈឧបករណ៍នេះ។ ជាលទ្ធផល "កម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ" ជាច្រើនបានរៀបចំដោយគ្មានគម្រោងវិនិយោគ(គម្រោងវិនិយោគវាខុសគ្នាពីសកម្មភាពជាប្រចាំ)និងមិនមានថវិកាគាំទ្រដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

គោលការណ៍ណែនាំថ្មីនឹងជួយកំណត់ឡើងវិញនូវកម្មវិធីវិនិយោគឱ្យស្របជាមួយបទពិសោធន៍ល្អៗ និងកំណត់កម្មវិធីវិនិយោគជាឧបករណ៍មួយសម្រាប់ចាត់អាទិភាពគម្រោងប្រៀបធៀបនឹងធនធានដែលរដ្ឋបាលថ្នាក់ក្រោមជាតិចង់កៀរគរ និងផ្តល់ថវិកាផ្ទាល់ខ្លួនសម្រាប់គាំទ្រគម្រោងទាំងមូល ឬផ្នែកខ្លះនៃគម្រោង។

### ៣.៤–កម្មវិធីប្រតិបត្តិការសេវាកម្ម (SOP)

កម្មវិធីប្រតិបត្តិការសេវាកម្ម គឺជាកម្មវិធីពាឆ្នាំរំកិល។ ការចាត់អាទិភាពកម្មវិធីប្រតិបត្តិការសេវកម្មផ្អែកលើធនធានដែលមាន ហើយការអនុវត្តកម្មវិធីប្រតិបត្តិការសេវាកម្មគឺជាផ្នែកមួយរបស់របៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន។

កម្មវិធីប្រតិបត្តិការសេវាកម្មមានការពាក់ព័ន្ធនឹងល័ក្ខខ័ណ្ឌបច្ចុប្បន្នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងជាពិសេសភាពច្បាស់លាស់នៃវិសាភាពការងាររបស់ទីចាត់ការ/ការិយាល័យអន្តរវិស័យ ឬការិយាល័យអភិវឌ្ឍន៍ក្រុង ដែលមានអាណត្តិក្នុងការផ្តល់សេវាកម្មនានា៕

ការបង្កើតឧបករណ៍រៀបចំគម្រោងនឹងជួយផ្តល់ឱកាសមួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់តួនាទីរបស់ខ្លួនក្នុងការផ្តល់សេវាកម្មនានា ដោយផ្អែកទៅលើមុខងារដែលប្រគល់ឱ្យដោយរដ្ឋបាលថ្នាក់ជាតិ និងមុខងារជាជម្រើសនៅក្នុងអាណត្តិទូទៅរបស់ខ្លួនដើម្បីឆ្លើយតបនឹងតម្រូវការ និងឱកាសក្នុងមូលដ្ឋាន។

## ៤–ដំណើរការកសាងផែនការ និងរៀបចំកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ៤.១–ដំណើរការកសាងផែនការ

គោលការណ៍ណែនាំថ្មី គួរតែបែងចែកដំណើរការកសាងផែនការ ជា៣ដំណាក់កាលធំៗ។ ដំណើរការកសាងផែនការបរិយាយតាមតារាងខាងក្រោម៖

| ដំណាក់កាល | ជំហាន | កិច្ចការ |
|---|---|---|
| 1. ការចាត់អាទិភាពយុទ្ធសាស្ត្រ | ▪ បង្កើតក្រុមការងារកសាងផែនការ (កកផ) | ▪ រៀបចំល័ក្ខខ័ណ្ឌការងារលម្អិតរបស់សមាជិកនីមួយៗរបស់ កកផ និងធនធានមនុស្សពីខាងក្រៅ<br>▪ កំណត់សមាជិកក្រុមការងារកសាងផែនការ<br>▪ ពង្រាង និងចេញដីកាបង្កើតក្រុមការងារកសាងផែនការ និងថវិកា<br>▪ ផ្តល់ការណែនាំដល់សមាជិកក្រុមការងារកសាងផែនការ (ដោយអ្នកសម្របសម្រួលជាមន្ទីរផែនការខេត្ត ឬអ្នកសម្របសម្រួលជាក្រសួងមហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន) |
| | ▪ កំណត់បញ្ហា និងឱកាស | – អនុម័តក្របខ័ណ្ឌកំណត់បញ្ហា (ដោយផ្តោតការយកចិត្តទុកដាក់លើវិស័យ និងអនុវិស័យដែលពាក់ព័ន្ធនឹងវិស័យធំទាំង៥របស់រដ្ឋបាលថ្នាក់ក្រោមជាតិ)<br>○ សង្គមកិច្ច<br>○ សេដ្ឋកិច្ច<br>○ រូបវ័ន្ត<br>○ បរិស្ថាន<br>○ ស្ថាប័ន |

| | | |
|---|---|---|
| | | – ពិនិត្យនិងចងក្រងព័ត៌មាន<br>○ ផែនការដែលមានស្រាប់របស់រដ្ឋបាលថ្នាក់ក្រោមជាតិកម្រិតក្រោម និងឃុំ សង្កាត់<br>○ ប្រព័ន្ធទិន្នន័យកសាងផែនការរបស់ក្រសួងផែនការ<br>○ ការវិភាគទិន្នន័យតាមវិស័យក្នុងមូលដ្ឋានដោយមន្ទីរជំនាញនានា<br>– ពង្រាង "បញ្ជីបញ្ហាទាំងអស់" ដែលជាការកំណត់បញ្ហា និងឱកាសលើកដំបូង |
| | ពិនិត្យឡើងវិញនូវការចាត់អាទិភាពជាយុទ្ធសាស្ត្រ | – កំណត់និងអញ្ជើញភាគីពាក់ព័ន្ធចូលរួមក្នុងវេទិកាកសាងផែនការ<br>– រៀបចំរចនាសម្ព័ន្ធវេទិកាកសាងផែនការឱ្យទៅជា៥ក្រុមការងារសម្រាប់វិស័យធំៗទាំង៥ខាងលើ<br>– រៀបចំសិក្ខាសាលាលើកទី១ (សិក្ខាសាលាមួយ សម្រាប់វិស័យមួយ)៖<br>○ ពិនិត្យឡើងវិញនូវបញ្ជីបញ្ហាលើកដំបូង ហើយកំណត់បញ្ហាសំខាន់ផ្សេងៗទៀត ។<br>○ ឯកភាពលើលក្ខណៈវិនិច្ឆ័យនិងបច្ចេកទេសសម្រាប់ចាត់អាទិភាព<br>– ចាត់អាទិភាពបញ្ហាជាពីរកម្រិត៖<br>○ មុខងារជាអាណត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ប្រតិភូកម្ម ឬប្រគល់ជូន)<br>○ ជម្រើសគោលនយោបាយនានារបស់ក្រុមប្រឹក្សាមូលដ្ឋាន<br>– ពង្រាងបឋម "បញ្ជីបញ្ហាអាទិភាព" ជាយុទ្ធសាស្ត្ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| 2. គោលដៅ និងទិសដៅ | រៀបចំគោលដៅ និងទិសដៅ | – ពិនិត្យបញ្ហាតាមវិស័យដែលមាននៅក្នុង "បញ្ជីអាទិភាព" ហើយកំណត់ហេតុ និងផល.<br>– កំណត់គោលនយោបាយនានាដើម្បីដោះស្រាយបញ្ហា ហើយសរសេរជាឃ្លា 'គោលដៅអភិវឌ្ឍន៍"<br>– កំណត់ទិសដៅ និងចំនុចដៅឱ្យស្របនឹងគោលដៅអភិវឌ្ឍន៍<br>– រៀបចំសិក្ខាសាលាលើកទី២<br>○ ពិនិត្យឡើងវិញ ហើយបញ្ចប់ការរៀបចំគោលដៅនិងចំនុចដៅ<br>○ រៀបចំសូចនាករវាស់វែង សម្រាប់គោលដៅ និងទិសដៅ (ចំនួនឬគុណភាព) |
| 3. គម្រោង,សេវាកម្ម,លិខិតបទដ្ឋានគតិយុត្ត | ពង្រាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងរបៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន | – ចាត់តាំងក្រុមរៀបចំសង្ខេបសកម្មភាពគម្រោងទៅតាមទិសដៅនីមួយៗ៖<br>○ <u>គម្រោងកម្មវិធីវិនិយោគ</u> (ដែលត្រូវអនុវត្តដោយថ្នាក់ជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ). |

| | | |
|---|---|---|
| | | ○ <u>ប្រតិបត្តិការសេវាកម្ម</u> (ដែលត្រូវអនុវត្តដោយរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ )<br>○ <u>លិខិតបទដ្ឋានគតិយុត្ត</u>(ដែលត្រូវអនុម័តដោយក្រុមប្រឹក្សា)<br>– រៀបចំពង្រាងសង្ខេបសកម្មភាពគម្រោង<br>– រៀបចំសិក្ខាសាលាលើកទី៣<br>○ ពិនិត្យនិងចាត់អាទិភាពគម្រោង សេវាកម្ម លិខិតបទដ្ឋានគតិយុត្ត<br>○ ឯកភាពទៅលើសកម្មភាពដែលត្រូវពិភាក្សាក្នុងការគាំថវិកា និងអនុវត្តដោយរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>○ ឯកភាពលើបញ្ជីសកម្មភាពចុងក្រោយដែលត្រូវដាក់បញ្ចូលក្នុងរបៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន<br>– ពង្រាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំដាក់ជូនគណៈកម្មាធិការកសាងផែនការ និងថវិកា<br>– ពង្រាងរបៀបវារៈអភិវឌ្ឍន៍មូលដ្ឋានដាក់ជូនគណៈកម្មាធិការកសាងផែនការ និងថវិកា |
| | អនុម័តផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងរបៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន | – ពិនិត្យនិងបញ្ចប់ការកសាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងរបៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន និងរៀបចំដីកាក្នុងមូលដ្ឋានសម្រាប់អនុម័ត។<br>– អនុម័តដីកាប្រើប្រាស់ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងរបៀបវារៈអភិវឌ្ឍន៍មូលដ្ឋានសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សា។ |

ការងារសំខាន់ពីរខុសគ្នាដែលទាក់ទងនឹងគោលការណ៍ណែនាំ និងការអនុវត្តបច្ចុប្បន្ន៖

ក) គួរផ្តល់ព័ត៌មាន និងពេលវេលាគ្រប់គ្រាន់ដល់ក្រុមប្រឹក្សា មុននឹងក្រុមប្រឹក្សាចេញ "គោលការណ៍ណែនាំគោលនយោបាយ" សម្រាប់រៀបចំផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ គោលការណ៍ណែនាំគោលនយបាយគួរឆ្លុះបញ្ចាំងបញ្ហា និងឱកាសជាអាទិភាពក្នុងមូលដ្ឋាន មិនមែនគ្រាន់តែយកតាមទិសដៅរបស់ថ្នាក់ជាតិ ឬទិសដៅសកលឡើយ (ឧទាហរណ៍៖ គោលដៅអភិវឌ្ឍន៍សហសវត្សរបស់ប្រទេសកម្ពុជា)។ ក្រុមប្រឹក្សាគួរចេញគោលការណ៍ណែនាំបន្ទាប់ពីបានកំណត់យុទ្ធសាស្ត្រជាអាទិភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ យុទ្ធសាស្ត្រជាអាទិភាពគួរតែស្របគ្នាជាមួយសេចក្តីប្រកាស "គោលការណ៍ណែនាំគោលនយោបាយ" របស់ក្រុមប្រឹក្សា។

ខ) ដំណើរការកសាងផែនការមិនគួរបញ្ចប់ត្រឹមការកំណត់ "យុទ្ធសាស្ត្រ"ទេ។ នៅក្នុងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងរបៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន គួរត្រូវរៀបចំសេចក្តីសង្ខេបសកម្មភាពគម្រោង សេវាកម្ម លិខិតបទដ្ឋានគតិយុត្ត និងនៅពេលដំណើរការរៀបចំកម្មវិធីប្រចាំឆ្នាំ ទើបចាប់ផ្តើមរៀបចំសេចក្តីលម្អិតការចាត់អាទិភាព និងការផ្គូរផ្គងគម្រោងជាមួយធនធាន។

### ៤.២-ដំណើរការរៀបចំកម្មវិធីវិនិយោគ

គោលការណ៍ណែនាំថ្មីនឹងជួយធ្វើឱ្យប្រសើរឡើងនូវភាពខ្វះចន្លោះក្នុងគោលការណ៍ណែនាំ និងការអនុវត្តបច្ចុប្បន្ន លើចំនុចមួយចំនួនដូចតទៅ៖

(ក) កំណត់យ៉ាងច្បាស់អំពីនិយមន័យកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលដាក់បញ្ចូលតែគម្រោងទាំងឡាយណាដែលគាំទ្រថវិដោយផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់គម្រោងទាំងមូល ឬ ផ្នែកខ្លះនៃគម្រោង ដែលវាខុសគ្នាពីការអនុវត្តបច្ចុប្បន្នបានដាក់បញ្ចូលគម្រោងដែលគាំទ្រថវិកាពីស្ថាប័នផ្សេងទៀត។
(ខ) ពង្រីកកម្មវិធីប្រតិបត្តិការសេវាកម្ម និង
(គ) ផ្តោតការយកចិត្តទុដាក់លើការផ្គូរផ្គងអាទិភាពគម្រោង និងកម្មវិធី ជាមួយធនធានដែលមាន និងផែនការជាក់លាក់ដែលអាចធ្វើទៅបានសម្រាប់កៀរគរធនធាន។
ដំណើរការរៀបចំកម្មវិធីវិនិយោគបរិយាយក្នុងតារាងខាងក្រោមដូចតទៅ៖

| ដំណើរការ | ជំហាន | ភារកិច្ច |
|---|---|---|
| ៤.ការរៀបចំកម្មវិធី | ▪ រៀបចំកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | – ចងក្រងទស្សនទានគម្រោង៖<br>○ សកម្មភាពគម្រោងដែលបានមកពីរបៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន<br>○ ធាតុចូលនានាដែលបានមកពីក្រុមធ្វើការតាមវិស័យនីមួយៗក្នុងវេទិកាកសាងផែនការ<br>○ ធាតុចូលនានាបានមកពីរដ្ឋថ្នាក់ក្រោមជាតិកម្រិតក្រោម និងឃុំសង្កាត់<br>– ការឯកភាពលើវិធីសាស្ត្រចាត់អាទិភាព និងគម្រោងអាទិភាពនៅក្នុងវេទិកាកសាងផែនការ<br>– ការប៉ាន់ប្រមាណតម្លៃគម្រោង<br>– ប៉ាន់ប្រមាណថវិកាគម្រោងដែលមានសម្រាប់គម្រោងនិងថវិកាដែលត្រូវកៀរគរបន្ថែម<br>– ផ្គូផ្គងតម្លៃជាមួយធនធាន និងបញ្ចប់ការរៀបចំកម្មវិធីវិនិយោគ<br>– រៀបចំ និងចេញដីកាអនុម័តការប្រើប្រាស់កម្មវិធីវិនិយោគ |
| | ▪ រៀបចំកម្មវិធីប្រតិបត្តិការសេវាកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | – ចងក្រងទស្សនកម្មវិធីផ្តល់សេវាកម្ម ដោយរួមបញ្ចូលទាំងការអភិវឌ្ឍសមត្ថភាព៖<br>○ សកម្មភាពសេវាកម្មដែលបានមកពីរបៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន |

| | | |
|---|---|---|
| | | ○ ធាតុចូលនានាបានមកពីក្រុមការងារតាមវិស័យនៃវេទិកាកសាងផែនការ<br>○ ធាតុចូលនានាបានមកពីរដ្ឋបាលថ្នាក់ក្រោមជាតិកម្រិតក្រោម និងឃុំ សង្កាត់<br>– ពិនិត្យនិងចាត់អាទិភាពកម្មវិធីផ្តល់សេវាកម្ម និងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងវេទិកាកសាងផែនការ<br>– ប៉ាន់ប្រមាណតម្លៃកម្មវិធី<br>– ប៉ាន់ប្រមាណថវិកាដែលមានសម្រាប់ការផ្តល់សេវាកម្ម និងការអភិវឌ្ឍសមត្ថភាព និងថវិកាដែលត្រូវកៀរគរបន្ថែម<br>– ផ្គូផ្គងតម្លៃជាមួយធនធាន និងបញ្ចប់ការរៀបចំកម្មវិធីប្រតិបត្តិការសេវាកម្ម<br>– រៀបចំនិងចេញដីកាអនុម័តការប្រើប្រាស់កម្មវិធីប្រតិបត្តិការសេវាកម្ម |

## ៥–ក្របខ័ណ្ឌពេលវេលាក្នុងការរៀបចំកម្មវិធីនិងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្របខ័ណ្ឌពេលវេលាក្នុងការរៀបចំ និងការធ្វើបច្ចុប្បន្នភាពកម្មវិធី និងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានអនុវត្តទៅដោយស្មុគស្មាញ និងកាលបរិច្ឆេទក្នុងការរៀបចំថវិកាប្រចាំឆ្នាំកំណត់ដោយច្បាប់ហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តរបស់ច្បាប់ហិរញ្ញវត្ថុ។

គោលការណ៍ណែនាំថ្មី គួរផ្តល់ពេលវេលារយៈពេលយ៉ាងហោចណាស់០៥ខែសម្រាប់កសាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងរបៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន។ ការកសាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងរបៀបវារៈអភិវឌ្ឍន៍មូលដ្ឋានគួរត្រូវបានបញ្ចប់ការរៀបចំក្នុងឆមាសទី២នៃអាណត្តិជាប់ឆ្នោតរបស់ក្រុមប្រឹក្សា។

ការរៀបចំ និងការធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំនៃកម្មវិធីវិនិយោគ និងកម្មវិធីប្រតិបត្តិការសេវាកម្មគួរមានរយៈពេល ២ខែ ហើយប្រព្រឹត្តទៅក្នុងត្រីមាសទីមួយជារៀងរាល់ឆ្នាំ។ ការរៀបចំកម្មវិធីទាំងនេះនឹងផ្តល់ព័ត៌មានដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបញ្ចប់ការរៀបចំផែនការថវិកានៅចុងខែមិថុនាសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់ និងអាចអនុវត្តនៅពេលចុងឆ្នាំ នៅពេលដែលថវិកានៃឆ្នាំសារពើពន្ធបានអនុម័តតាមច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

សេចក្តីសម្រេចក្នុងការបន្ស៊ីគ្នារវាងវដ្តក្នុងការកសាងផែនការ កម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាមួយស្ថាប័ននានារបស់រដ្ឋបាលថ្នាក់ជាតិមានសារៈសំខាន់ក្នុងដំណើរការកសាងផែនការ កម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការបន្ស៊ីក្របខ័ណ្ឌពេលវេលាកសាងផែនការឃុំ សង្កាត់ជាមួយក្របខ័ណ្ឌពេលវេលាក្នុងរៀបចំផែនការ កម្មវិធីរបស់ក្រុង ស្រុកនឹងផ្តល់ឱកាសក្នុងការសម្របសម្រួល ឬការដាក់បញ្ចូលគ្នានូវផែនការ កម្មវិធីរវាងក្រុង ស្រុកជាមួយនឹងឃុំ សង្កាត់។

គោលការណ៍ណែនាំថ្មី ឬការកែសម្រួលគោលការណ៍ណែនាំគួរបញ្ជាក់ពីការផ្លាស់ប្តូរក្របខ័ណ្ឌពេលវេលាក្នុងការកសាងផែនការឃុំ សង្កាត់។

## ៦–ប្រព័ន្ធគាំទ្រការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ការអភិវឌ្ឍសមត្ថភាពការសាងផែនការ និងការពង្រឹងគុណភាពកសាងផែនការកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពឹងផ្អែកទៅលើការរៀបចំប្រព័ន្ធគាំទ្រជាតិមួយដែលប្រកបដោយប្រសិទ្ធភាព ដែលមានវិសាលភាពមិនត្រឹមតែការគាំទ្រការកសាងផែនការ កម្មវិធីទេ ថែមទាំងជួយគាំទ្រដល់ការរៀបចំថវិកា ដើម្បីធានាបាននូវយុទ្ធសាស្ត្រសព្វជ្រុងជ្រោយមួយក្នុងការគ្រប់គ្រងការចំណាយសាធារណៈ។ ការរៀបចំប្រព័ន្ធគាំទ្រនឹងជួយដោះស្រាយការយល់ច្រឡំតួនាទីស្ថាប័ននានានៃរដ្ឋបាលថ្នាក់ជាតិដែលពាក់ព័ន្ធ។

ស្ថាប័នចំនួន៤ មានតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រ និងត្រួតពិនិត្យប្រព័ន្ធកសាងផែនការ កម្មវិធី និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន៖

- ក្រសួងផែនការ (MOP)
- ក្រសួងមហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (MOI/DOLA)
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន (MEF/LFD)
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ /អគ្គនាយកដ្ឋានរតនាគារជាតិ(MEF/GDNT)

### ៦.១–ក្រសួងផែនការ (MOP)

យោងតាមការកសាងផែនការថ្នាក់ក្រោមជាតិ ក្រសួងផែនការមានតួនាទីពីរ៖ (ក)ទី១ គឺផ្សព្វផ្សាយបទពិសោធន៍ល្អៗរួមបញ្ចូលទាំងវិធីសាស្ត្រ និងបច្ចេកទេសកសាងផែនការដល់រដ្ឋបាលគ្រប់កម្រិត និង (ខ)ទី២ គឺធានាថាផែនការថ្នាក់ក្រោមជាតិឆ្លើយតបនឹងផែនការថ្នាក់ជាតិ និងការសម្របសម្រួលផែនការជាតិជាមួយកម្មវិធីវិនិយោគសាធារណៈជាតិ។ តួនាទីទី២នេះ ក្រសួងផែនការនឹងផ្តល់សេវាកម្មសម្រមសម្រួល និងអភិវឌ្ឍន៍សមត្ថភាពនៅថ្នាក់រាជធានី និងតំបន់ (ខេត្ត)។

**ក្រសួងផែនការគួរមានតួនាទីជាក់លាក់ដូចខាងក្រោម៖**

- រួមសហការជាមួយក្រសួងមហាផ្ទៃ រៀបចំ និងចេញប្រកាស ច្បាប់ លិខិតបទដ្ឋានគតិយុត្តសម្រាប់កសាងផែនការថ្នាក់ក្រោមជាតិដល់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិត
- ចេញគោលកាណ៍ណែនាំ សៀវភៅណែនាំ ក្នុងការកសាងផែនការ កម្មវិធីថ្នាក់រាជធានី តំបន់(ខេត្ត) និងគាំទ្រការកសាងផែនការ កម្មវិធីថ្នាក់រាជធានី តំបន់ (ខេត្ត)
- បង្កើតក្រុមដែលមានជំនាញក្នុងការសម្របសម្រួលការកសាងផែនការ និងចាត់តាំងអ្នកសម្របសម្រួលជួយដល់ក្រុមការងារកសាងផែនការរាជធានី ខេត្ត។

- ផ្តល់សេវកម្មគាំទ្របច្ចេកទេស និងព័ត៌មានពីប្រព័ន្ធទិន្នន័យកសាងផែនការរបស់ក្រសួងផែនការដល់ក្រុមការងារកសាងផែនការគ្រប់កម្រិត
- ជួយគាំទ្រដល់ក្រសួងមហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្នុងការរៀបចំបង្កើតគោលការណ៍ណែនាំសៀវភៅណែនាំសម្រាប់ការកសាងផែនការ កម្មវិធីថ្នាក់ក្រុង ស្រុក។

## ៦.២–**ក្រសួងមហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន** (MOI/DOLA)

យោងតាមការកសាងផែនការថ្នាក់ក្រោមជាតិ ក្រសួមហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន មានតួនាទីទូទៅក្នុងការអភិវឌ្ឍសមត្ថភាព ត្រួតពិនិត្យការអនុវត្ត ពិនិត្យទីត្យានុកូលភាពលើការបំពេញការងារ (ដោយរួមបញ្ចូលការអនុម័តផែនការ និងកម្មវិធី)របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ សមត្ថភាពកសាងផែនការនៅក្នុងកម្រិតស្រុក ក្រុង និងឃុំ សង្កាត់ នៅមានកម្រិតនៅឡើយ។ ក្រសួងមហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលមូលដ្ឋានផ្តល់សេវាកម្មសម្របសម្រួល និងអភិវឌ្ឍន៍សមត្ថភាពកសាងផែនការ កម្មវិធីនៅថ្នាក់ក្រុង ស្រុក។

**ក្រសួងមាហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលមានតួនាទីជាក់លាក់ដូចខាងក្រោម៖**

- រួមសហការជាមួយក្រសួងផែនការ រៀបចំ និងចេញប្រកាស ច្បាប់ លិខិតបទដ្ឋានគតិយុត្តសម្រាប់កសាងផែនការថ្នាក់ក្រោមជាតិដល់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិត
- ចេញគោលកាណ៍ណែនាំ សៀវភៅណែនាំ ក្នុងការកសាងផែនការ កម្មវិធីថ្នាក់ក្រុង ស្រុក និងគាំទ្រការកសាងផែនការ កម្មវិធីថ្នាក់ក្រុង ស្រុក
- បង្កើតក្រុមដែលមានជំនាញក្នុងការសម្របសម្រួលការងារកសាងផែនការ និងចាត់តាំងអ្នកសម្របសម្រួលជួយដល់ក្រុមការងារកសាងផែនការក្រុង ស្រុក
- ពិនិត្យនីត្យានុកូលភាពលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាស្តីពីដំណើរការ និងឧបករណ៍កសាងផែនការ
- ត្រួតពិនិត្យការបំពេញការអនុវត្តផែនការ កម្មវិធី និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៦.៣–**ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ/នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន**

អាណត្តិរបស់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺអភិវឌ្ឍន៍និងផ្សព្វផ្សាយបទពិសោធន៍ល្អៗក្នុងការរៀបចំថវិកាដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងឃុំ សង្កាត់ ហើយនឹងជំរុញការគ្រប់គ្រងការចំណាយសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋានមានតួនាទីជាក់លាក់ដូចតទៅ៖**

- រួមសហការជាមួយរតនាគារជាតិរៀបចំបង្កើតក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ
- ចេញគោលការណ៍ណែនាំ
  សៀវភៅណែនាំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិតស្តីពីការប្រតិបត្តិការថវិកានានា (ការរៀបចំការប្រគល់សិទ្ធិការអនុវត្ត និងគណនេយ្យភាព)
- ពិនិត្យនីត្យានុកូលភាពដោយផ្ទាល់ ឬតាមការប្រតិភូកម្មទៅឱ្យអភិបាលខេត្តទៅលើថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៦.៤–ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/អគ្គនាយកដ្ឋានរតនាគារជាតិ(MEF/GDNT)

អាណត្តិរបស់អគ្គនាយកដ្ឋានរតនាគារជាតិ គឺផ្តល់សេវាកម្មគ្រប់គ្រងសាច់ប្រាក់ គណនេយ្យសាធារណៈ និងគាំទ្រការប្រើងប្រែងកៀរគរធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (រួមសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ នាយកដ្ឋានពន្ធដារ)

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/អគ្គនាយកដ្ឋានរតនាគារជាតិមានការទទួលខុសត្រូវជាក់លាក់ដូចតទៅ៖**

- ចេញគោលការណ៍ណែនាំ សៀវភៅណែនាំ ស្តីពី(១)ការទូទាត់ និងគ្រប់គ្រងសាច់ប្រាក់(២)ការប៉ាន់ប្រមាណនិងការប្រមូលចំណូលមូលដ្ឋាន
- ត្រួតពិនិត្យលិខិតបទដ្ឋានគតិយុត្តក្នុងប្រតិបត្តិការថវិកា (ចំណូល និងចំណាយ) របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ស្ថាប័នទាំង៤ខាងលើអាចបង្កើតទៅជា "**ក្រុមការងារ**" កសាងផែនការ កម្មវិធី និងថវិកាសម្រាប់ថ្នាក់ក្រោមជាតិ ដែលស្ថិតក្នុងក្របខ័ណ្ឌ គ.ជ.អ.ប. ក្នុងគោលបំណងបង្កើតយន្តការរួមមួយដើម្បីអភិវឌ្ឍន៍សមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងធានាបាននូវភាពស៊ីចង្វាក់គ្នាក្នុងការរៀបចំសៀវភៅណែនាំនីមួយៗ។

# គ.ជ.អ.ប.

**អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ**

**(ដឹកនាំដោយ: ក្រសួងផែនការ)**

## ក្របខ័ណ្ឌគោលនយោបាយផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**ឯកសារគោលនយោបាយណែនាំតម្រង់ទិស**
**ការកែសម្រួលសេចក្ដីណែនាំ និងលិខិតបទដ្ឋានគតិយុត្តបច្ចុប្បន្ន**

## មាតិកា

- គោលបំណង និងវិសាលភាពឯកសារគោលនយោបាយ
- មូលហេតុអ្វីបានជាចាំបាច់ត្រូវកែសម្រួលលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចុប្បន្ន?
- គោលការណ៍នៃផែនការថ្នាក់ក្រោមជាតិតាមប្រព័ន្ធវិមជ្ឈការ
- សំណើក្របខ័ណ្ឌគោលនយោបាយផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

## គោលបំណង និងវិសាលភាពឯកសារគោលនយោបាយ

- **គោលបំណង**
  - ផ្ដល់ការណែនាំតម្រង់ទិសគោលនយោបាយក្នុងការ**កែទម្រង់ប្រព័ន្ធផែនការ**របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។
  - ផ្ដល់ការណែនាំតម្រង់ទិសដល់ការ**កែសម្រួលគោលការណ៍ណែនាំ** និង **លិខិតបទដ្ឋានគតិយុត្តបច្ចុប្បន្ន**និងជួយផ្លាស់ប្ដូរប្រព័ន្ធផែនការមជ្ឈការឱ្យទៅជា**ប្រព័ន្ធផែនការវិមជ្ឈការ** ។
  - **សំណើផ្លាស់ប្ដូរ** ប្រព័ន្ធកសាងផែនការ ស្ថាប័ន ឧបករណ៍ ដំណើរការ ក្របខ័ណ្ឌពេលវេលា និងប្រព័ន្ធគាំទ្រផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

## គោលបំណង និងវិសាលភាពឯកសារគោលនយោបាយ

- **វិសាលភាព**
  - មិនគ្របដណ្ដប់ដោយផ្ទាល់ទៅលើការ**រៀបចំឧបករណ៍លំអិត ដំណើរការ** កសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទេ ។
  - មិនគ្របដណ្ដប់លើដំណើរ**ការកសាងផែនការឃុំ សង្កាត់ទេ** ។ ប៉ុន្តែត្រូវ**ការបន្សីុគ្នា ក្របខ័ណ្ឌពេលវេលា** រវាងផែនការ ខេត្ត ក្រុង ស្រុក ខណ្ឌ ជាមួយនឹងឃុំ សង្កាត់ ។
  - មិនគ្របដណ្ដប់ការរៀបចំឧបករណ៍ **ផែនការរូបវ័ន្ត និងលិខិតបទដ្ឋានគតិយុត្ត** ("ក្របខ័ណ្ឌ បែងចែកតំបន់អភិវឌ្ឍន៍" និង "ផែនការគ្រប់គ្រងការប្រើប្រាស់ដីធ្លី")របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។
  - មិនគ្របដណ្ដប់លើដំណើរ**ការរៀបចំថវិកា**របស់រដ្ឋបាលថ្នាក់ក្រោមជាតិទេ ។ ប៉ុន្តែការអនុវត្តឧបករណ៍ និងក្របខ័ណ្ឌពេលវេលាក្នុងរៀបចំថវិកានឹងពាក់ព័ន្ធជាមួយជាមួយ នឹងដំណើរការកសាងផែនការ កម្មវិធី ។

### មូលហេតុអ្វីបានជាចាំបាច់ត្រូវកែសម្រួលលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចុប្បន្ន?

- **លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំ**
  - **សេចក្តីណែនាំបច្ចេកទេស** ស្តីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
  - **សេចក្តីណែនាំបច្ចេកទេស** ស្តីពីការកសាងកម្មវិធីវិនិយោគរាជធានី ខេត្ត
  - **សេចក្តីណែនាំបច្ចេកទេស** ស្តីពីការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
  - **សេចក្តីណែនាំបច្ចេកទេស** ស្តីពីការកសាងកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ។

### មូលហេតុអ្វីបានជាចាំបាច់ត្រូវកែសម្រួលលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចុប្បន្ន?

- **លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំ**
  - **អនុក្រឹត្យលេខ ២១៩** ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៩)
  - **អនុក្រឹត្យលេខ ២១៧** ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សារាជធានី និងខណ្ឌ
  - **អនុក្រឹត្យលេខ ២១៨** ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាខេត្ត ក្រុង និងស្រុក

### មូលហេតុអ្វីបានជាចាំបាច់ត្រូវកែសម្រួលលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចុប្បន្ន?

- **ភាពខ្វះចន្លោះលិខិតបទដ្ឋានគតិយុត្ត និងការអនុវត្ត**
  - មានពេលវេលាខ្លីក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំលើកទី១ សម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
  - **ខ្វះខាតក្របខ័ណ្ឌច្បាប់**ពាក់ព័ន្ធនឹងហិរញ្ញវត្ថុថ្នាក់ ក្រោមជាតិ និង **ការពន្យាពេលការអនុម័តមូលនិធិក្រុង ស្រុក** និងការផ្ទេរធនធានដែលអាចអនុវត្តកម្មវិធីនៅមូលដ្ឋាន។
  - លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចុប្បន្នពុំបានបង្ហាញពី**ភាពខុសគ្នារវាងធនធាន**របស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយបានបន្តអនុវត្តផែនការរបស់ថ្នាក់ក្រោមជាតិថាជាដំណើរការមួយ"ក្នុងការប្រែក្លាយផែនការជាតិឱ្យទៅជាផែនការសម្រាប់អនុវត្តក្នុងមូលដ្ឋាន"

### មូលហេតុអ្វីបានជាចាំបាច់ត្រូវកែសម្រួលលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចុប្បន្ន?

- **ភាពខ្វះចន្លោះលិខិតបទដ្ឋានគតិយុត្ត និង ការអនុវត្ត**
  - ពុំទាន់បានផ្តល់សារៈសំខាន់អំពី**ស្វ័យភាព**ក្នុងការរៀបចំផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។
  - ពុំបានគោរពតាមច្បាប់អង្គការទាំងស្រុងនៅឡើយ............ហើយច្បាប់អង្គការក៏មិនបានបកស្រាយច្បាស់លាស់អំពី**ការប្រើប្រាស់ធនធានផ្ទាល់ខ្លួន**របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។
  - **"ផែនការតាមដែនសមត្ថកិច្ច"** ឬ "ផែនការតាមដែនសមត្ថកិច្ចទូទៅ" ដែលត្រូវអនុវត្តពីគ្រប់ភាគីពាក់ព័ន្ធស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

### មូលហេតុអ្វីបានជាចាំបាច់ត្រូវកែសម្រួលលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចុប្បន្ន?

- **ភាពខ្វះចន្លោះលិខិតបទដ្ឋានគតិយុត្ត និង ការអនុវត្ត**
  - **“ផែនការផ្ទាល់”** (corporate) របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវប្រើប្រាស់ធនធានផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។
  - **ដោះស្រាយការច្រឡំច្រូល**គ្នារវាង “ផែនការដែនសមត្ថកិច្ច” និង “ផែនការផ្ទាល់” របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។
  - **លើកកម្ពស់ថាមពលរួមគ្នា**រវាងការប្រឹងប្រែងផ្ទាល់ខ្លួនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងរដ្ឋបាលថ្នាក់ជាតិ អង្គការ វិស័យឯកជន

### គោលការណ៍នៃផែនការថ្នាក់ក្រោមជាតិតាមប្រព័ន្ធវិមជ្ឈការ

**១.ផែនការ និងស្វ័យភាពមូលដ្ឋាន**

- រដ្ឋបាលថ្នាក់ក្រោមជាតិជា **“នីតិបុគ្គល”** ដែលដំណើរការក្នុងក្របខ័ណ្ឌច្បាប់ជាតិ និងស្ថិតក្រោមការត្រួតពិនិត្យនីត្យានុកូលភាពរបស់រដ្ឋ ។
- **ព្រំដែនស្វ័យភាព**របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបាន**កំណត់ដោយលិខិតបទដ្ឋានគតិយុត្ត និងច្បាប់ជាតិ** ហើយភ្នាក់ងារនៃរដ្ឋបាលថ្នាក់ជាតិទទួលខុសត្រូវគ្រប់គ្រងត្រួតពិនិត្យ ។

### គោលការណ៍នៃផែនការថ្នាក់ក្រោមជាតិតាមប្រព័ន្ធវិមជ្ឈការ

**១.ផែនការ និងស្វ័យភាពមូលដ្ឋាន**

- រដ្ឋបាលថ្នាក់ក្រោមជាតិគួរតែអនុវត្តឱ្យមានប្រសិទ្ធភាពក្នុងការផ្តល់សេវាកម្មនានា និងតួនាទីជាក់លាក់ សម្រាប់វិស័យផ្សេងៗទៀត**ដែលចាត់តាំង ឬប្រតិភូកម្មឱ្យដោយរដ្ឋបាលថ្នាក់ជាតិ** ។
- រដ្ឋបាលថ្នាក់ក្រោមជាតិ គួរតែ**អនុវត្តអំណាចស្វ័យភាព**របស់ខ្លួនក្នុងការសម្រេចប្រើប្រាស់ធនធានដែលផ្ទេរឱ្យដោយថ្នាក់ជាតិ ឬធនធានផ្ទាល់ខ្លួន និង**មុខងារជាជម្រើសរបស់ខ្លួន** ដើម្បីឆ្លើយតបតម្រូវការជាអាទិភាពក្នុងមូលដ្ឋាន ។

### គោលការណ៍នៃផែនការថ្នាក់ក្រោមជាតិតាមប្រព័ន្ធវិមជ្ឈការ

**២. ផែនការ និងអភិបាលកិច្ចច្រើនជាន់ថ្នាក់**

- កំណែទម្រង់វិមជ្ឈការកំពុងតែផ្លាស់ប្តូរអភិបាលកិច្ចរបស់ប្រទេសប្រព័ន្ធរដ្ឋបាលសាធារណៈឱ្យទៅជាប្រព័ន្ធច្រើនកំរិត ដែល**នីតិបុគ្គលនីមួយៗ**ទទួលខុសត្រូវក្នុងការ**រៀបចំគោលនយោបាយ** និង**អនុវត្តកិច្ចសហការក្នុងកម្រិតនីមួយៗ** និងកម្រិតផ្សេងគ្នាទៅតាមរចនាសម្ព័ន្ធរបស់រដ្ឋ/ប្រទេស ។
- រដ្ឋបាលថ្នាក់ជាតិ**មិនមែនជាអ្នកទទួលខុសត្រូវផ្តាច់មុខ** ក្នុងការកសាងផែនការ ការផ្តល់សេវាកម្មនិងហិរញ្ញវត្ថុប៉ុន្តែជា**ការចែករំលែកការទទួលខុសត្រូវ**ប្រកបដោយប្រសិទ្ធភាពរវាងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងស្ថាប័នផ្សេងៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

## គោលការណ៍នៃផែនការថ្នាក់ក្រោមជាតិតាមប្រព័ន្ធវិមជ្ឈការ

**២. ផែនការ និងអភិបាលកិច្ចច្រើនជាន់ថ្នាក់**

- អភិបាលកិច្ច (វិមជ្ឈការ)ច្រើនជាន់ថ្នាក់នឹងប្រើប្រាស់**<u>យន្តការមួយថ្មី</u>** ដែលមានការ**<u>ពិគ្រោះយោបល់ និងចរចា</u>** ដូចជាការត្រួតពិនិត្យនីត្យានុកូលភាពទៅលើស្វ័យភាពរបស់នីតិបុគ្គលថ្មីនានា ។
- **<u>ឧបករណ៍ និងដំណើរការកសាងផែនការស្វ័យភាព</u>**របស់រដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងយន្តការសម្របសម្រួលខ្សែទទឹង និងខ្សែបណ្ដោយរបស់ថ្នាក់ក្រោមជាតិជាមួយអ្នកពាក់ព័ន្ធគ្រប់កម្រិត (ភ្នាក់ងារ រដ្ឋបាលថ្នាក់ជាតិ រដ្ឋបាល ថ្នាក់ក្រោមជាតិផ្សេងៗទៀត និងឃុំសង្កាត់ វិស័យឯកជននិងអង្គការនានា) នៅ**<u>ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។</u>**

4

## គោលការណ៍នៃផែនការថ្នាក់ក្រោមជាតិតាមប្រព័ន្ធវិមជ្ឈការ

**២. ការកសាងផែនការតាមប្រព័ន្ធដែនដីផ្សេងៗគ្នា**

ការគ្រប់គ្រងនឹងអនុវត្តទៅតាមអនុប្រព័ន្ធដែនដីនីមួយៗរួមមាន៖

- រាជធានីភ្នំពេញ
- ខេត្ត
- ក្រុង និង
- ស្រុក

## ប្រព័ន្ធកសាងផែនការ

- **<u>ផែនការតំបន់ (ខេត្ត)</u>** (សម្របសម្រួលរវាង ខេត្ត/ ស្រុក/ ក្រុង)
- **<u>ផែនការរាជធានី</u>** (ដាក់បញ្ចូលគ្នារវាង  រាជធានី/ខណ្ឌ/សង្កាត់)
- **<u>ផែនការក្រុង</u>** (ដាក់បញ្ចូលគ្នារវាង ក្រុង/សង្កាត់)
- **<u>ផែនការជនបទ/ស្រុក</u>** (សម្របសម្រួលរវាង ស្រុក/ឃុំ/សង្កាត់)

## ប្រព័ន្ធកសាងផែនការ



## ស្ថាប័នកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**គណៈកម្មាធិការកសាងផែនការនិងថវិកា (គផថ)របស់ក្រុមប្រឹក្សា**

គណៈកម្មាធិការកសាងផែនការ និងថវិកាមានសារៈសំខាន់ដូចតទៅ៖

(i) ជួយក្រុមប្រឹក្សាឱ្យបានចូលរួមពេញលេញក្នុងដំណើរការកសាងផែនការ ដែលមិនមែនគ្រាន់តែចូលរួមនៅពេលចាប់ផ្តើមនិងពេលបញ្ចប់ទេ។

(ii) អភិវឌ្ឍន៍សមត្ថភាពដល់តំណាងក្រុមប្រឹក្សាក្នុងការគ្រប់គ្រងត្រួតពិនិត្យដំណើរការកសាងផែនការ និង ការវាយតម្លៃលទ្ធផល។ គណៈកម្មធិការកសាងផែនការ និងថវិកាជួយផ្តល់ព័ត៌មាន និងវិភាគជូនដល់ ក្រុមប្រឹក្សា ក្នុងការធ្វើសេចក្តីសម្រេចបានសមស្រប។

(iii) ជួយសម្របសម្រួលសកម្មភាពរវាងក្រុមប្រឹក្សាកម្រិតផ្សេងៗគ្នារបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅវិញទៅមក និងក្រុមប្រឹក្សាឃុំ សង្កាត់ តាមរយៈកិច្ចប្រជុំរួមគ្នា និងការផ្តល់អនុសាន៍រួមគ្នាដើម្បីទទួលបានសេចក្តីសម្រេចចុងក្រោយពីក្រុមប្រឹក្សាកម្រិតផ្សេងៗគ្នា។

## ស្ថាប័នកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**វេទិកាកសាងផែនការ**

វេទិកាផែនការថ្នាក់ខេត្ត គួរតែ**ដឹកនាំដោយអភិបាលខេត្ត** ហើយសមាសភាពចូលរួមក្នុងវេទិកាផែនការថ្នាក់ខេត្តរួមមាន៖

- អភិបាល ស្រុក ក្រុង ទាំងអស់ក្នុងខេត្ត
- ប្រធានគណៈកម្មាធិការផែនការនិងថវិការបស់ក្រុមប្រឹក្សា
- តំណាងអង្គការនានាដែលប្រតិបត្តិការក្នុងខេត្ត (ចំនួនមិនតិចជាង X% នៃកៅអីសរុប)
- តំណាងមន្ទីរជំនាញនានាក្នុងខេត្ត
- ផ្សេងៗ (តំណាងក្រុមប្រឹក្សា)

## ស្ថាប័នកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**វេទិកាកសាងផែនការ**

វេទិកាកសាងផែនការ ស្រុក ក្រុង គួរតែ**ដឹកនាំដោយអភិបាលស្រុក ក្រុង** ហើយសមាសភាពចូលរួមក្នុងវេទិកាផែនការថ្នាក់ស្រុក ក្រុង រួមមាន៖

- ប្រធានក្រុមប្រឹក្សា ឃុំ សង្កាត់ ទាំងអស់ក្នុង ស្រុក ក្រុង
- ប្រធានគណៈកម្មាធិការផែនការថវិកា របស់ក្រុមប្រឹក្សា ស្រុក ក្រុង
- តំណាងអង្គការនានាដែលប្រតិបត្តិការក្នុងស្រុក ក្រុង (ចំនួនមិនតិចជាង X% នៃកៅអីសរុប)
- តំណាងមន្ទីរជំនាញនានា ក្នុងស្រុក ក្រុង
- ផ្សេងៗ (តំណាងក្រុមប្រឹក្សា)

## ស្ថាប័នកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**ក្រុមការងារកសាងផែនការ**



## ស្ថាប័នកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**<u>ក្រុមការងារកសាងផែនការ</u>**

- ការងារគ្រប់គ្រងប្រចាំថ្ងៃរបស់ក្រុមការងារកសាងផែនការគួរស្ថិតនៅ**<u>ក្រោមការដឹកនាំរបស់ទីចាត់ការ/ការិយាល័យ</u>** ផែនការហើយរាយការណ៍ដោយផ្ទាល់ជូនអភិបាល ។
- ក្រុមសម្របសម្រួលមួយ គួរត្រូវបានបង្កើតឡើងនៅ**<u>មន្ទីរជំនាញផែនការខេត្ត</u>** ដើម្បីគាំទ្រផ្ទាល់ដល់**<u>ការកសាងផែនការរាជធានី និងតំបន់/ខេត្ត</u>** និងនៅ**<u>ស្ទួងមហាផ្ទៃ/នាយកដ្ឋានអង្គភាពរដ្ឋបាលមូលដ្ឋាន</u>** ដើម្បីគាំទ្រផ្ទាល់ដល់ការកសាងផែនការ**<u>ប្រជុំជន/ក្រុងនិងជនបទ/ស្រុក ។</u>**
- **<u>ការផ្តល់លទ្ធភាពបត់បែន</u>**ដល់ក្រុមការងារកសាងផែការស្វែងរកជំនួយគាំទ្រ**<u>បច្ចេកទេសពីខាងក្រៅ</u>**

## ឧបករណ៍សម្រាប់កសាងផែនការ និងការរៀបចំកម្មវិធីតាមវិស័យ

ការលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំនឹងជួយដល់រដ្ឋបាលថ្នាក់ក្រោមជាតិបង្កើតឧបករណ៍ចំនួន៤សម្រាប់ ៖

- ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ <u>"ផែនការតាមដែនសមត្ថកិច្ច"</u> (៥ឆ្នាំ)
- របៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន <u>"ផែនការផ្ទាល់"</u> របស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ (៥ ឆ្នាំ)
- កម្មវិធីវិនិយោគ (៣ឆ្នាំ)
- កម្មវិធីប្រតិបត្តិការសេវាកម្ម (៣ឆ្នាំ)

## ដំណើរការកសាងផែនការ និងរៀបចំកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

គោលការណ៍ណែនាំថ្មី គួរតែបែងចែកដំណើរការកសាងផែនការ ជា៤ដំណាក់កាលធំៗ ។ ដំណើរការកសាងផែនការបរិយាយតាមតារាងខាងក្រោម៖

<u>១. ការចាត់អាទិភាពយុទ្ធសាស្ត្រ</u>
- បង្កើតក្រុមការងារកសាងផែនការ (កកផ)
- កំណត់បញ្ហា និងឱកាស
- ពិនិត្យឡើងវិញនូវការចាត់អាទិភាពជាយុទ្ធសាស្ត្រ

<u>២. គោលដៅ និងទិសដៅ</u>
- រៀបចំគោលដៅ និងទិសដៅ

<u>៣. គម្រោង,សេវាកម្ម,លិខិតបទដ្ឋានគតិយុត្ត</u>
- ពង្រាងផែនការអភិវឌ្ឍន៍រយៈ ពេល៥ឆ្នាំ និងរបៀបវារៈ អភិវឌ្ឍន៍មូលដ្ឋាន
- អនុម័តផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងរបៀបវារៈ អភិវឌ្ឍន៍មូលដ្ឋាន

<u>៤. ការរៀបចំកម្មវិធី</u>
- រៀបចំកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំកម្មវិធីប្រតិបត្តិការសេវាកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

## ក្របខ័ណ្ឌពេលវេលាក្នុងការរៀបចំកម្មវិធីនិងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ផ្តល់ពេលវេលាយ៉ាងហោចណាស់**<u>០៥ខែ</u>**សម្រាប់កសាងផែនការអភិវឌ្ឍន៍ ។
- ការរៀបចំ និងការធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំនៃកម្មវិធីវិនិយោគ និងកម្មវិធីប្រតិបត្តិការសេវាកម្មគួរមានរយៈពេល**<u>០២ខែ</u>** ហើយប្រព្រឹត្តទៅក្នុងត្រីមាសទីមួយជារៀងរាល់ឆ្នាំ ។
- **<u>ការបន្ស៊ីក្របខ័ណ្ឌពេលវេលា</u>**កសាងផែនការឃុំ សង្កាត់ជាមួយក្របខ័ណ្ឌពេលវេលាក្នុងរៀបចំផែនការ កម្មវិធីរបស់ក្រុង ស្រុកនឹងផ្តល់ឱកាសក្នុងការសម្របសម្រួល ឬការដាក់បញ្ចូលគ្នានូវផែនការ កម្មវិធីរវាងក្រុង ស្រុកជាមួយនឹងឃុំ សង្កាត់ ។

### ប្រព័ន្ធគាំទ្រការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**១.ក្រសួងផែនការ** (MOP)

**ក្រសួងផែនការគួរមានតួនាទីជាក់លាក់ដូចខាងក្រោម៖**

- <u>**រួមសហការ**</u>ជាមួយក្រសួងមហាផ្ទៃ រៀបចំ និងចេញប្រកាស ច្បាប់លិខិតបទដ្ឋានគតិយុត្តសម្រាប់កសាងផែនការថ្នាក់ក្រោមជាតិដល់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិត ។
- <u>**ចេញគោលការណ៍ណែនាំ សៀវភៅណែនាំ**</u> ក្នុងការកសាងផែនការ កម្មវិធីថ្នាក់រាជធានី តំបន់(ខេត្ត) និង គាំទ្រការកសាងផែនការ កម្មវិធីថ្នាក់រាជធានី តំបន់ (ខេត្ត) ។
- <u>**បង្កើតក្រុម**</u>ដែលមានជំនាញក្នុងការ<u>**សម្របសម្រួលការកសាងផែនការ**</u> និងចាត់តាំងអ្នកសម្របសម្រួល ជួយដល់ក្រុមការងារកសាងផែនការរាជធានី ខេត្ត ។

### ប្រព័ន្ធគាំទ្រការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**២.ក្រសួងផែនការ** (MOP)

**ក្រសួងផែនការគួរមានតួនាទីជាក់លាក់ដូចខាងក្រោម៖**

- ផ្តល់សេវាកម្មគាំទ្រ<u>**បច្ចេកទេស**</u> និង<u>**ព័ត៌មាន**</u>ពីប្រព័ន្ធទិន្នន័យកសាងផែនការរបស់ក្រសួងផែនការដល់ <u>**ក្រុមការងារកសាងផែនការគ្រប់កម្រិត ។**</u>
- <u>**ជួយគាំទ្រដល់**</u>ក្រសួងមហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្នុងការរៀបចំបង្កើត<u>**គោលការណ៍ណែនាំ សៀវភៅណែនាំ**</u>សម្រាប់ការកសាងផែនការ កម្មវិធីថ្នាក់ក្រុង ស្រុក ។

### ប្រព័ន្ធគាំទ្រការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**ក្រសួងមហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន** (MOI/DOLA)

**ក្រសួងមាហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលមានតួនាទីជាក់លាក់ដូចខាងក្រោម៖**

- <u>**រួមសហការ**</u>ជាមួយក្រសួងផែនការ រៀបចំ និងចេញប្រកាស ច្បាប់លិខិតបទដ្ឋានគតិយុត្តសម្រាប់កសាង ផែនការថ្នាក់ក្រោមជាតិដល់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិត
- <u>**ចេញគោលការណ៍ណែនាំ សៀវភៅណែនាំ**</u> ក្នុងការកសាងផែនការ កម្មវិធី ថ្នាក់ក្រុង ស្រុក និង<u>**គាំទ្រ**</u>ការកសាងផែនការ កម្មវិធីថ្នាក់ក្រុង ស្រុក

### ប្រព័ន្ធគាំទ្រការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**ក្រសួងមហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន** (MOI/DOLA)

**ក្រសួងមាហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលមានតួនាទីជាក់លាក់ដូចខាងក្រោម៖**

- <u>**បង្កើតក្រុម**</u>ដែលមានជំនាញក្នុងការ<u>**សម្របសម្រួលការងារ**</u>កសាងផែនការ និងចាត់តាំងអ្នកសម្របសម្រួល ជួយដល់ក្រុមការងារកសាងផែនការក្រុង ស្រុក ។
- <u>**ពិនិត្យនីត្យានុកូលភាព**</u>លើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាស្តីពីដំណើរការ និងឧបករណ៍កសាងផែនការ ។
- <u>**ត្រួតពិនិត្យ**</u>ការបំពេញការអនុវត្តផែនការ កម្មវិធី និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

## ប្រព័ន្ធគាំទ្រការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ/នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋានមានតួនាទីជាក់លាក់ដូចតទៅ៖**

- **<u>រួមសហការ</u>**ជាមួយរតនាគារជាតិរៀបចំបង្កើតក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ។
- **<u>ចេញគោលការណ៍ណែនាំ សៀវភៅណែនាំ</u>**សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិតស្តីពីការប្រតិបត្តិការថវិកានានា (ការរៀបចំការប្រគល់សិទ្ធិការអនុវត្ត និងគណនេយ្យភាព) ។
- **<u>ពិនិត្យនីត្យានុកូលភាព</u>**ដោយ**<u>ផ្ទាល់</u>** ឬតាម**<u>ការប្រតិភូកម្ម</u>**ទៅឱ្យអភិបាលខេត្តទៅលើថវិការបស់រដ្ឋបាល ថ្នាក់ក្រោមជាតិ ។

## ប្រព័ន្ធគាំទ្រការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/អគ្គនាយកដ្ឋានរតនាគារជាតិ**

(MEF/GDNT)

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/អគ្គនាយកដ្ឋានរតនាគារជាតិមានការទទួលខុសត្រូវជាក់លាក់ដូចតទៅ៖**

- **<u>ចេញគោលការណ៍ណែនាំ សៀវភៅណែនាំ</u>** ស្តីពី (១)ការទូទាត់ និងគ្រប់គ្រងសាច់ប្រាក់ (២)ការប៉ាន់ប្រមាណ និងការប្រមូលចំណូលមូលដ្ឋាន ។
- **<u>ត្រួតពិនិត្យ</u>**លិខិតបទដ្ឋានគតិយុត្តក្នុងប្រតិបត្តិការថវិកា (ចំណូល និងចំណាយ) របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

# អរគុណ !!!